**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# តួនាទី និងភារកិច្ចរបស់ចៅក្រមស៊ើបសួរ

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយនិស្សិតឈ្មោះ

**កញ្ញា ឈាន មួយជូរ**

**លោក យ៉ាន សុភ័ណ្ឌ**

សាស្ត្រាចារ្យណែនាំ

**លោក ជួន ប៊ុនធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# តួនាទី និងភារកិច្ចរបស់ចៅក្រមស៊ើបសួរ

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយនិស្សិតឈ្មោះ

**កញ្ញា ឈាន មួយជូរ**

**លោក យ៉ាន សុភ័ណ្ឌា**

សាស្ត្រាចារ្យណែនាំ

**លោក ជួន ប៊ុនធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីររូបឈ្មោះ **ឈាន មួយង៉ុរ** និង **យ៉ាន សុភ័ណ្ឌា** ជានិស្សិតផ្នែកនីតិសាស្ត្រ ជំនាន់ទី២១ ក្រុម **L4A1** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

យើងខ្ញុំសូមគោរពដឹងគុណ និងថ្លែងអំណរគុណដ៏វិសេសវិសាលដែលមិនអាចប្រៀបផ្ទឹមបានដល់លោកឪពុកអ្នកម្តាយជាទីស្រឡាញ់របស់កូនៗ ដែលបានបង្កើត ចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅដល់កូនៗប្រកបដោយព្រហ្មវិហារធម៌ទាំងបួន។ ជាពិសេសនៅពេលសម្រាកពីការងារ ទោះបីមានការនឿយហត់ក៏ដោយ លោកទាំងពីរតែងតែផ្តល់នូវសេចក្តីស្រឡាញ់ ថ្នាក់ថ្នម យកចិត្តទុកដាក់ ថែមទាំងព្រួយបារម្ភគ្រប់ពេលពីសុខទុក្ខរបស់កូនៗជានិច្ច។ មិនយូរប៉ុន្មានដល់ពេលកូនៗចម្រើនវ័យត្រូវទទួលការអប់រំពីសាលា លោកទាំងពីរក៏បានបញ្ជូនកូនៗទៅសាលារៀន ដើម្បីទទួលបាននូវការអប់រំផ្នែកចំណេះដឹងទូទៅ ដោយមិនគិតពីការចំណាយចាយវាយទាំងឡាយ មិនត្រឹមតែប៉ុណ្ណោះលោកទាំងពីររឹតតែខិតខំទាំងកម្លាំងកាយចិត្ត ដោយភ្លេចការនឿយហត់ដើម្បីទំនុកបម្រុងកូនៗឱ្យបានរៀនសូត្រក្រេបយកចំណេះដឹង។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស-រង សាស្ត្រាចារ្យ ព្រមទាំងបុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាតឱ្យយើងខ្ញុំបានចូលមកសិក្សានៅសាកលវិទ្យាល័យមួយនេះ និងជាពិសេសបានផ្តល់ឱកាសដល់យើងខ្ញុំបានចូលរួមក្នុងការសរសេរសារណាបញ្ចប់ឆ្នាំសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនេះ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសាស្ត្រាចារ្យ **ជួន ម៉ុនធី** សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលលោកបានយល់ព្រមក្នុងការដឹកនាំសារណារបស់យើងខ្ញុំទាំងពីរ ជាពិសេសលោកបានខិតខំចំណាយពេលវេលាដ៏មានតម្លៃក្នុងការបង្ហាត់បង្រៀន ផ្តល់ដំបូន្មានល្អៗ លើកទឹកចិត្ត និងណែនាំដល់យើងខ្ញុំឱ្យខិតខំប្រឹងប្រែងធ្វើកិច្ចការសារណានេះឱ្យទទួលបានជោគជ័យ។

ជាចុងក្រោយ យើងខ្ញុំទាំងពីរសូមលើកហត្ថាប្រណមបួងសួងសុំដល់ទេវតា និងវត្ថុស័ក្តិសិទ្ធិទាំងអស់ដែលមាននៅក្នុងលោកនេះ សូមតាមជួយថែរក្សា លោកឪពុកអ្នកម្តាយ ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាស្ត្រាចារ្យ និងមិត្តភក្តិរួមជំនាន់ទាំងអស់ឱ្យជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ព្រមទាំងទទួលបាននូវសុខសុភមង្គល ទទួលទានមានបានក្នុងក្រុមគ្រួសារ និងជោគជ័យគ្រប់ភារកិច្ច។

# អារម្ភកថា

យើងខ្ញុំឈ្មោះ **ឈាន មួយជូរ** និង **យ៉ាន សុភ័ណ្ឌ** ជានិស្សិតផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី២១។ យើងខ្ញុំបានឆ្លងកាត់ការសិក្សា និងទទួលបានការបណ្តុះបណ្តាលលើជំនាញនីតិសាស្ត្រអស់រយៈពេលបួនឆ្នាំមកហើយ ការសិក្សារយៈពេលបួនឆ្នាំនេះ យើងខ្ញុំបានឆ្លងកាត់នូវបទពិសោធន៍ជាច្រើន ដែលបទពិសោធន៍ទាំងនោះជាចំណែកមួយក្នុងការធ្វើឱ្យយើងខ្ញុំបានអភិវឌ្ឍខ្លួនកាន់តែប្រសើរ រហូតឈានដល់ការបញ្ចប់ថ្នាក់បរិញ្ញាបត្រ។ លើសពីនេះទៅទៀត យើងខ្ញុំជ្រើសរើសយកការសរសេរសារណាដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រ ព្រោះវាជាឱកាសដ៏ល្អសម្រាប់យើងខ្ញុំក្នុងការបង្កើតនូវស្នាដៃមួយដែលអាចសបញ្ជាក់អំពីការខិតខំប្រឹងប្រែង ព្រមទាំងចំណេះដឹងដែលយើងខ្ញុំទទួលបានពីការសិក្សាកន្លងមក។

ការសិក្សានៅថ្នាក់បរិញ្ញាបត្រនេះ យើងខ្ញុំបានរៀនសូត្រនូវមុខវិជ្ជាជាច្រើន ដែលសុទ្ធសឹងតែទាក់ទងទៅនឹងជំនាញដែលយើងខ្ញុំសិក្សា ក្នុងចំណោមមុខវិជ្ជាទាំងអស់ យើងខ្ញុំមានចំណាប់អារម្មណ៍យ៉ាងខ្លាំងទៅលើមុខវិជ្ជានីតិវិធីព្រហ្មទណ្ឌ ដែលជាមុខវិជ្ជាមួយនៅក្នុងចំណោមមុខវិជ្ជាដែលសំខាន់ៗដទៃទៀត ព្រមទាំងជាមុខវិជ្ជាដែលបង្ហាញអំពីវិធានក្នុងការអនុវត្តទាក់ទងទៅនឹងដំណាក់កាលទាំងបួនក្នុងរឿងក្តីព្រហ្មទណ្ឌ ហើយយើងខ្ញុំក៏សម្រេចចិត្តជ្រើសរើសយកដំណាក់កាលស៊ើបសួរមកធ្វើការសិក្សាស្រាវជ្រាវ។ ដូច្នេះ យើងខ្ញុំបានជ្រើសរើសយកប្រធានបទស្តីអំពី **“តួនាទី និងភារកិច្ចរបស់ចៅក្រមស៊ើបសួរ”** មកធ្វើការសិក្សាស្រាវជ្រាវ។

មូលហេតុដែលយើងខ្ញុំធ្វើការស្រាវជ្រាវទៅលើប្រធានបទនេះ ដោយសារដំណាក់កាលស៊ើបសួរ គឺជាដំណាក់កាលមួយសំខាន់ក្នុងចំណោមដំណាក់កាលផ្សេងៗទៀត ដែលមានវត្តមានចៅក្រមស៊ើបសួរ ដើរតួនាទីយ៉ាងសំខាន់ ព្រមទាំងស្រាវជ្រាវរកការពិតនៃរឿងក្តី រហូតដល់បិទបញ្ចប់នីតិវិធីនៃការស៊ើបសួរ។ យើងខ្ញុំសង្ឃឹមថា ស្នាដៃមួយនេះនឹងអាចចូលរួមចំណែកលើកស្ទួយចំណេះដឹងទាក់ទងទៅនឹងតួនាទី និងភារកិច្ចរបស់ចៅក្រមស៊ើបសួរតាមរយៈខ្លឹមសារដែលបានបកស្រាយ ជាពិសេសប្រធានបទនេះ អាចជាជំនួយដល់ប្អូនៗនិស្សិតច្បាប់ជំនាន់ក្រោយ ទុកជាឯកសារ ឬជាជំនួយស្មារតី ដល់ប្អូនៗក្នុងការស្រាវជ្រាវ ឬចង់ស្វែងយល់បន្ថែម។

យ៉ាងណាមិញ ការស្រាវជ្រាវលើប្រធានមួយនេះ គឺពិតជានៅមានចំណុចខ្វះខាត ទាំងពាក្យពេចន៍ និងអត្ថន័យខ្លឹមសារ អាស្រ័យហេតុនេះ សូមលោក លោកស្រីសាស្ត្រាចារ្យ សិស្សនិស្សិត ព្រមទាំងមិត្តអ្នកអានទាំងអស់ មេត្តាខន្តីអភ័យទោសដល់ការស្រាវជ្រាវរបស់យើងខ្ញុំទាំងពីរផង។ យើងខ្ញុំទាំងពីរមានសេចក្តីត្រេកអរយ៉ាងក្រៃលែង ក្នុងការទទួលយកនូវការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់លោក លោកស្រីសាស្ត្រាចារ្យ សិស្សនិស្សិត និងមិត្តអ្នកអានទាំងអស់ ដើម្បីចូលរួមចំណែកក្នុងការកែលម្អ ឬកែប្រែនូវចំណុចខ្វះខាតក្នុងកិច្ចការស្រាវជ្រាវមួយនេះ ឱ្យកាន់តែមានអត្ថន័យខ្លឹមសារល្អប្រសើរថែមទៀត។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ................................................ ១

## ជំពូកទី១
## ទំនាក់ទំនងចៅក្រមស៊ើបសួរ និងកិច្ចស៊ើបសួរ

**ផ្នែកទី១៖ សញ្ញាណទូទៅរបស់ចៅក្រមស៊ើបសួរ** ................................................ ៣

**កថាខណ្ឌទី១៖ ចៅក្រមស៊ើបសួរ** ................................................ ៣

ក. ចៅក្រមស៊ើបសួរជាអ្នកណា? ................................................ ៣

ខ. ការស៊ើបសួរដាក់បន្ទុក និងដោះបន្ទុករបស់ចៅក្រមស៊ើបសួរ ................................................ ៤

**កថាខណ្ឌទី២៖ គោលការណ៍នៃការស៊ើបសួរ** ................................................ ៤

ក. ការសម្ងាត់ក្នុងការស៊ើបសួរ ................................................ ៤

ខ. ឯករាជ្យភាពនៃការស៊ើបសួរ ................................................ ៥

គ. វិសមិតភាពមុខងារ ................................................ ៥

ឃ. សមត្ថកិច្ចដែនដី ................................................ ៥

**ផ្នែកទី២៖ ការបើកការស៊ើបសួរ និងការប្តឹងទៅចៅក្រមស៊ើបសួរ** ................................................ ៦

**កថាខណ្ឌទី១៖ បែបបទនៃបណ្តឹង** ................................................ ៦

ក. សេចក្តីសន្និដ្ឋានឱ្យបើកការស៊ើបសួររបស់អយ្យការ ................................................ ៦

ខ. បណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ................................................ ៧

**កថាខណ្ឌទី២៖ អានុភាពនៃបណ្តឹង** ................................................ ៨

ក. ភាពមិនអាចដកបណ្តឹងបាន ................................................ ៨

ខ. កាតព្វកិច្ចស៊ើបសួរ ................................................ ៩

គ. វិសាលភាពនៃការប្តឹង ................................................ ៩

## ជំពូកទី២
## ដំណើរការស៊ើបសួររបស់ចៅក្រមស៊ើបសួរ

**ផ្នែកទី១៖ វិធីសាស្ត្រស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ** ................................................ ១០

**កថាខណ្ឌទី១៖ ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ** ................................................ ១០

ក. ការជូនដំណឹងអំពីការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ ................................................ ១០

ខ. ការសួរចម្លើយជនត្រូវចោទ ..... ១១
គ. ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី..... ១២
ឃ. ការស្តាប់ចម្លើយសាក្សី..... ១៣
ង. ការឆែកឆេរ និងការចាប់យកវត្ថុតាង ..... ១៤
ច. ការធ្វើកោសលវិច័យ..... ១៤
ឆ. ការស្តាប់ទូរស័ព្ទ ..... ១៦
ជ. ដីកាចាត់ឱ្យស៊ើបសួរជំនួស..... ១៧
**កថាខណ្ឌទី២៖ ការស្នើសុំបំពេញកិច្ច**..... ១៧
ក. ព្រះរាជអាជ្ញា..... ១៧
ខ. ដើមបណ្តឹងរដ្ឋប្បវេណី ..... ១៨
គ. ជនត្រូវចោទ ..... ១៨
**ផ្នែកទី២៖ វិធានការនិរន្តរាយ** ..... ១៨
**កថាខណ្ឌទី១៖ ដីកាបង្គាប់ឱ្យចូលខ្លួន**..... ១៩
**កថាខណ្ឌទី២៖ ដីកាបង្គាប់ឱ្យនាំខ្លួន** ..... ១៩
**កថាខណ្ឌទី៣៖ ដីកាបង្គាប់ឱ្យចាប់ខ្លួន**..... ២០
**កថាខណ្ឌទី៤៖ ការឃុំខ្លួនបណ្តោះអាសន្ន**..... ២១
ក. មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន..... ២២
ខ. ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន..... ២២
គ. ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ..... ២៤
ឃ. តាមបណ្តឹងរបស់ព្រះរាជអាជ្ញា និងជនត្រូវចោទ ..... ២៤
ង. ការជូនដំណឹងអំពីការដោះលែងឱ្យនៅក្រៅឃុំ ..... ២៥
**កថាខណ្ឌទី៥៖ ដីកាបង្គាប់ឱ្យឃុំខ្លួន** ..... ២៦
**កថាខណ្ឌទី៦៖ ដីកាសម្រេចឱ្យដាក់ស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ** ..... ២៦
ក. លក្ខខណ្ឌគ្រឹះនៃការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ..... ២៦
ខ. មូលហេតុនៃការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ..... ២៧
**កថាខណ្ឌទី៧៖ ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការ**..... ២៩
ក. ដោយចៅក្រមស៊ើបសួរ ..... ២៩

ខ. ដោយព្រះរាជអាជ្ញា ........ ២៩
គ. ដោយជនត្រូវចោទ ........ ២៩
**កថាខណ្ឌទី៨៖ ការគេចវេះពីភាតព្វកិច្ច** ........ ២៩

## ជំពូកទី៣

## ការបិទការស៊ើបសួរ

**ផ្នែកទី១៖ នីតិវិធីនៃការបិទការស៊ើបសួរ** ........ ៣១
**កថាខណ្ឌទី១៖ ការជូនព័ត៌មានដោយចៅក្រមស៊ើបសួរ** ........ ៣១
ក. ការជូនដំណឹងដល់គូភាគី ........ ៣១
ខ. ការស្នើសុំបំពេញកិច្ចបន្ថែម ........ ៣២
**កថាខណ្ឌទី២៖ ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា** ........ ៣២
**ផ្នែកទី២៖ ប្រភេទដីកាដំណោះស្រាយ** ........ ៣៣
**កថាខណ្ឌទី១៖ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ** ........ ៣៤
**កថាខណ្ឌទី២៖ ដីកាលើកលែងការចោទប្រកាន់** ........ ៣៥
**កថាខណ្ឌទី៣៖ ការបើកការស៊ើបសួរលើបន្ទុកថ្មី** ........ ៣៦
**សេចក្តីសន្និដ្ឋាន** ........ ៣៧
**អនុសាសន៍** ........ ៣៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

យើងធ្លាប់បានដឹងហើយថា ប្រទេសកម្ពុជាយើងធ្លាប់មានប្រព័ន្ធចៅក្រមស៊ើបសួរដំបូងក្រោមឈ្មោះថា សាលានីតិកម្មស៊ើបសួរ ឬសុភាចារបុរស តាមបញ្ញត្តិនៃក្រមពិភាក្សាព្រហ្មទណ្ឌមុនរបបប្រល័យពូជសាសន៍ខ្មែរក្រហម។ ក្រោយមកទៀតបានប្តូរឈ្មោះថា ចៅក្រមស៊ើបសួរ តាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣។ បច្ចុប្បន្នយើងឃើញថា ប្រព័ន្ធចៅក្រមស៊ើបសួរនៅកម្ពុជា មានមន្ទីរស៊ើបសួរមួយ គឺជាយុត្តាធិការស៊ើបសួរនៃសាលាដំបូងដែលមានចៅក្រមជាច្រើនរូប មានអំណាចស៊ើបសួរទៅលើរឿងក្តីទាំងឡាយដែលប្តឹងចោទបើកការស៊ើបសួរតាមរយៈដីកាបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ឬតាមរយៈដើមបណ្តឹងរដ្ឋប្បវេណី។ ដោយឡែកនៅសាលាឧទ្ធរណ៍ មានសភាស៊ើបសួរមួយដែលមានចៅក្រមជាច្រើនរូប។ មិនតែប៉ុណ្ណោះ ចៅក្រមស៊ើបសួរមានតួនាទីយ៉ាងសំខាន់ក្នុងវិស័យយុត្តាធិការ ជាអ្នកស្វែងរកភាពយុត្តិធម៌ក្នុងនាមតុលាការជូនភាគី ព្រោះចៅក្រមស៊ើបសួរមានករណីយកិច្ចស៊ើបសួរទាំងដាក់បន្ទុក ទាំងដោះបន្ទុក។ ជាពិសេសនោះ ចៅក្រមស៊ើបសួរមានតួនាទីភារកិច្ចក្នុងការស្រាវជ្រាវស្វែងរកភស្តុតាង ឬការពិតនៃរឿងក្តី រហូតដល់បិទបញ្ចប់នីតិវិធីនៃការស៊ើបសួរ។ ក្នុងនោះដែរ យើងឃើញថាក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាយើងបច្ចុប្បន្ន បានស្តែងឱ្យឃើញថា មានដំណាក់កាលជាច្រើនដែលដាច់ដោយឡែកពីគ្នា រួមមានដំណាក់កាលស៊ើបអង្កេតត្រូវធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ បន្ទាប់មកដំណាក់កាលចោទប្រកាន់ត្រូវធ្វើឡើងដោយព្រះរាជអាជ្ញា ហើយដំណាក់កាលស៊ើបសួរត្រូវធ្វើឡើងដោយចៅក្រមស៊ើបសួរ និងដំណាក់កាលចុងក្រោយនោះគឺ ដំណាក់កាលជំនុំជម្រះ ឬលើកលែងការចោទប្រកាន់ រហូតដល់ការប្រកាសសាលក្រមស្ថាពរ។

ដោយយើងពិនិត្យទៅលើដំណាក់កាលទាំងអស់ខាងលើ យើងអាចឃើញថា ដំណាក់កាលចៅក្រមស៊ើបសួរ គឺជាដំណាក់កាលមួយដែលស្ថិតនៅបន្ទាប់ពីដំណាក់កាលចោទប្រកាន់របស់តំណាងអយ្យការ ហើយដំណាក់កាលស៊ើបសួរនេះមានសារៈសំខាន់ណាស់។ យើងដឹងហើយថា មុននឹងឈានដល់ការស៊ើបសួរ លុះត្រាតែមានការចោទប្រកាន់ឱ្យបើកការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ការបើកការស៊ើបសួរនេះទៀតសោត ចៅក្រមស៊ើបសួរត្រូវបើកការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ក្នុងការស្វែងរកការពិតនៃអង្គហេតុ ដែលបង្ហាញអំពីអត្ថិភាពនៃបទល្មើស ដែលចោទប្រកាន់ដោយព្រះរាជអាជ្ញាក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ចៅក្រមស៊ើបសួរ ត្រូវស៊ើបសួរតែទៅលើអង្គហេតុដែលបានកំណត់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាតែប៉ុណ្ណោះ។ ម្យ៉ាងទៀត អំណាចរបស់ចៅក្រមស៊ើបសួរដែលបានផ្តល់ដោយក្រមនីតិវិធីព្រហ្មទណ្ឌ រួមមានអំណាចក្នុងការស្រាវជ្រាវរកការពិតនៃរឿងហេតុដែលទាក់ទងនឹងបទល្មើសព្រហ្មទណ្ឌ ព្រមទាំងសិទ្ធិអំណាចក្នុងការអនុវត្តវិធានការ

និរន្តរាយដែលចៅក្រមស៊ើបសួរអាចចេញនូវដីកាមួយចំនួនដូចជា ដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំខ្លួន ដីកាបង្គាប់ឱ្យចាប់ខ្លួន ដីកាឃុំខ្លួនបណ្តោះអាសន្ន និងការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ជាដើម។

គោលបំណងក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទ "**តួនាទី និងភារកិច្ចរបស់ចៅក្រមស៊ើបសួរ**" នេះគឺចង់សិក្សាឱ្យកាន់តែស៊ីជម្រៅ ហើយកាន់តែលម្អិតទាក់ទងទៅនឹងតួនាទី ព្រមទាំងភារកិច្ចរបស់ចៅក្រមស៊ើបសួរ នៅក្នុងសំណុំរឿងព្រហ្មទណ្ឌ។ ការស្រាវជ្រាវនេះ គឺយើងខ្ញុំផ្តោតសំខាន់តែទៅលើតួនាទី និងភារកិច្ចរបស់ចៅក្រមស៊ើបសួរតែប៉ុណ្ណោះ។ ដូច្នេះចំណោទបញ្ហានៅត្រង់ថា តើចៅក្រមស៊ើបសួរជាអ្នកណា ? តើចៅក្រមស៊ើបសួរមានតួនាទី និងភារកិច្ចអ្វីខ្លះនៅក្នុងកិច្ចស៊ើបសួរនៅដំណាក់កាលសាលាដំបូងចំពោះរឿងក្តីព្រហ្មទណ្ឌ ?

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទ "**តួនាទី និងភារកិច្ចរបស់ចៅក្រមស៊ើបសួរ**" ពិតជាមានសារៈសំខាន់ណាស់ ចំពោះដំណើរនៃការស្វែងយល់អំពីនីតិវិធីព្រហ្មទណ្ឌ ដោយសារតែដំណាក់កាលស៊ើបសួរ គឺជាដំណាក់កាលមួយ ដែលស្មុគស្មាញ ក៏ដូចជាមានកិច្ចស៊ើបសួរជាច្រើនដែលទាក់ទងទៅនឹងការបង្ហាញការពិតនៃរឿងក្តីព្រហ្មទណ្ឌ។

ការសិក្សាស្រាវជ្រាវនេះ ធ្វើឡើងតាមរយៈការប្រមូលនូវបទដ្ឋានគតិយុត្ត និងឯកសារនានា ដែលទាក់ទងទៅនឹងប្រធានបទ ជាពិសេសគឺផ្តោតសំខាន់ទៅលើក្រមនីតិវិធីព្រហ្មទណ្ឌ ដែលមានចែងអំពីដំណាក់កាលស៊ើបសួរនៃរឿងក្តីព្រហ្មទណ្ឌ។ រាល់ខ្លឹមសារ ក៏ដូចជាការពន្យល់នៅក្នុងអត្ថបទស្រាវជ្រាវ គឺត្រូវប្រាកដថាពិតប្រាកដ ព្រមទាំងមានប្រភពច្បាស់លាស់ ក៏ដូចជាអនុលោមទៅតាមមាត្រាដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ ដើម្បីបកស្រាយទៅលើប្រធានបទ **"តួនាទី និងភារកិច្ចរបស់ចៅក្រមស៊ើបសួរ"** នៃសារណានេះឱ្យកាន់តែស៊ីជម្រៅ និងច្បាស់លាស់ថែមទៀតនោះ យើងនឹងធ្វើការបកស្រាយទៅលើចំណុចសំខាន់ៗដូចតទៅ៖

**ជំពូកទី១ ទំនាក់ទំនងចៅក្រមស៊ើបសួរ និងកិច្ចស៊ើបសួរ**

**ជំពូកទី២ ដំណើរការស៊ើបសួររបស់ចៅក្រមស៊ើបសួរ**

**ជំពូកទី៣ ការបិទការស៊ើបសួរ**

# ជំពូកទី១
# ទំនាក់ទំនងចៅក្រមស៊ើបសួរ និងកិច្ចស៊ើបសួរ

ដើម្បីជាភាពងាយស្រួលក្នុងការសិក្សាស្វែងយល់អំពីតួនាទីនិងភារកិច្ចរបស់ចៅក្រមស៊ើបសួរ ដូចដែលមានក្នុងកិច្ចនីតិវិធីស្រាវជ្រាវរកបទល្មើសនៅក្នុងរឿងក្តីព្រហ្មទណ្ឌ គឺគប្បីយល់ដឹងផងដែរថាចៅក្រមដែលទទួលភារកិច្ចក្នុងការស៊ើបសួរ ត្រូវតែជាចៅក្រមអាសនៈដែលស្ថិតក្នុងយុត្តាធិការស៊ើបសួរ។ នៅពេលដែលមានអំពើមួយកើតឡើង ហើយត្រូវបានកំណត់ថាជាបទល្មើសព្រហ្មទណ្ឌ នោះតែងតែឃើញមានវត្តមានមន្ត្រីនគរបាលយុត្តិធម៌ចូលរួមក្នុងការស៊ើបអង្កេត ព្រមទាំងមានការចោទប្រកាន់ដោយធ្វើឡើងពីតំណាងអយ្យការ។ ក្រោយពីមានការចោទប្រកាន់ដោយតំណាងអយ្យការ ការស៊ើបសួរនឹងត្រូវបានកើតឡើងស្របទៅតាមបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលតម្រូវឱ្យចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួរនេះ។

## ផ្នែកទី១៖ សញ្ញាណទូទៅរបស់ចៅក្រមស៊ើបសួរ

មន្ទីរស៊ើបសួរនៃសាលាដំបូង គឺជាផ្នែកមួយនៃតុលាការព្រហ្មទណ្ឌ និងមានសមត្ថកិច្ចស៊ើបសួររឿងក្តីព្រហ្មទណ្ឌ ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនិតិវិធីព្រហ្មទណ្ឌ។ ប្រធានសាលាដំបូងត្រូវចាត់តាំងចៅក្រមយ៉ាងតិច ០២ (ពីរ) រូប តាមដីកាសម្រេចឱ្យបំពេញតួនាទីជាចៅក្រមស៊ើបសួរនៅមន្ទីរស៊ើបសួរនៃតុលាការព្រហ្មទណ្ឌនៃសាលាដំបូង។ ដីកាសម្រេចនេះត្រូវកំណត់ផងដែរអំពីលំដាប់លេខរៀងសម្រាប់ការទទួលបំពេញការងារ។ ក្នុងករណីពុំមានចៅក្រមស៊ើបសួរ ឬខ្វះចៅក្រមស៊ើបសួរ ប្រធានសាលាដំបូងអាចចាត់តាំងចៅក្រមនៃតុលាការជំនាញផ្សេង ដើម្បីបំពេញមុខងារស៊ើបសួរបាន។[1]

### កថាខណ្ឌទី១៖ ចៅក្រមស៊ើបសួរ

#### ក. ចៅក្រមស៊ើបសួរជាអ្នកណា?

ចៅក្រមស៊ើបសួរ គឺជាចៅក្រមដែលបំពេញភារកិច្ចក្នុងការស៊ើបសួរ និងការស្រាវជ្រាវស្វែងរកនូវភស្តុតាងដែលទាក់ទងទៅនឹងសំណុំរឿងព្រហ្មទណ្ឌ ក្នុងគោលបំណងបង្ហាញឱ្យឃើញនូវការពិត និងផ្តល់យុត្តិធម៌ទៅកាន់ភាគីដែលពាក់ព័ន្ធ។

នៅក្នុងសាលាដំបូងរាជធានី-ខេត្ត ចៅក្រមស៊ើបសួរត្រូវបានចាត់តាំងដោយប្រធានតុលាការ។ កាលណាចៅក្រមស៊ើបសួរណាម្នាក់ ពុំអាចបំពេញមុខងាររបស់ខ្លួនបានទេ ដោយសារការឈប់សម្រាក ដោយមានជំងឺ ឬដោយមានមូលហេតុដទៃផ្សេងទៀត ចៅក្រមស៊ើបសួរផ្សេងទៀតនៃតុលាការដដែល ត្រូវបានចាត់តាំងជា

[1] ច្បាប់រៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា ២០។

បណ្តោះអាសន្ន ដោយប្រធានតុលាការ ដើម្បីបំពេញមុខងារស៊ើបសួរ។[2]

ចំពោះការបែងចែកសំណុំរឿង ប្រសិនបើនៅក្នុងតុលាការមានចៅក្រមស៊ើបសួរច្រើនរូប សំណុំរឿងទាំងឡាយត្រូវបានបែងចែកដោយប្រធានតុលាការ។[3]

### ខ. ការស៊ើបសួរដាក់បន្ទុក និងដោះបន្ទុករបស់ចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរមានករណីកិច្ចស៊ើបសួរទាំងដាក់បន្ទុក និងដោះបន្ទុក[4] ដោយធ្វើការស្វែងរកភស្តុតាងនានា ដោយអនុលោមតាមវិធាននីតិវិធីដ៏តឹងរឹង ដើម្បីធានាឱ្យបាននូវរឿងក្តីមួយប្រកបដោយសមធម៌។ ភស្តុតាងត្រូវតែមានទំនាក់ទំនងជាមួយនឹងសំណុំរឿងនោះ ដែលភស្តុតាងអាចជាសាក្សី ឯកសារ សំលេង សេចក្តីសន្និដ្ឋានរបស់អ្នកជំនាញ និងរបាយការណ៍នានាដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌។ ភស្តុតាងទាំងអស់សុទ្ធតែត្រូវបានបង្ហាញ និងពិភាក្សាដោយចំពោះមុខ ដោយគូភាគីទាំងអស់នៅក្នុងដំណាក់កាលនៃការស៊ើបសួរនៅចំពោះមុខចៅក្រមស៊ើបសួរ។

## កថាខណ្ឌទី២៖ គោលការណ៍នៃការស៊ើបសួរ

នៅដំណាក់កាលស៊ើបសួរ ចៅក្រមស៊ើបសួរធ្វើការស៊ើបសួរដោយស្របទៅតាមគោលការណ៍ដែលបានកំណត់នូវក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។

### ក. ការសម្ងាត់ក្នុងការស៊ើបសួរ

ការស៊ើបសួរត្រូវតែជាការសម្ងាត់។ បុគ្គលទាំងឡាយដែលចូលរួមក្នុងការស៊ើបសួរ ជាពិសេសចៅក្រម មេធាវី ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ មន្ត្រីរាជការ អ្នកជំនាញ អ្នកបកប្រែ គ្រូពេទ្យ និងបុគ្គលដែលមានសមត្ថកិច្ចដូចចែងក្នុងមាត្រា ៩៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវរក្សាការសម្ងាត់នៃវិជ្ជាជីវៈ។ ប៉ុន្តែ ការគោរពនូវការសម្ងាត់វិជ្ជាជីវៈ មិនអាចជាឧបសគ្គដល់ការប្រើសិទ្ធិនៃការការពារខ្លួនឡើយ។

ម៉្យាងទៀត ព្រះរាជអាជ្ញាអាចធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ កាលណាខ្លួនយល់ឃើញថាព័ត៌មានដែលផ្សព្វផ្សាយពីរឿងណាមួយនោះ ជាព័ត៌មានមិនពិត។ ការបំពានលើការសម្ងាត់នៃការស៊ើបសួរ គឺជាបទល្មើសដែលត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។[5]

---

[2] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ៥១។

[3] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ៥២។

[4] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១២៧។

[5] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១២១។

**ខ. ឯករាជ្យភាពនៃការស៊ើបសួរ**

ចៅក្រមស៊ើបសួរត្រូវតែទទួលបាននូវឯករាជ្យភាពយ៉ាងពេញលេញក្នុងការស៊ើបសួរ ដោយឯករាជ្យនោះត្រូវតែបង្ហាញអំពីសិទ្ធិក្នុងការសម្រេចថាធ្វើ ឬមិនធ្វើអ្វីមួយដែលពាក់ព័ន្ធនឹងសំណុំរឿងព្រហ្មទណ្ឌដែលទទួលបន្ទុកស៊ើបសួរ ស្របទៅតាមឆន្ទានុសិទ្ធិ និងសម្បជញ្ញៈរបស់ចៅក្រម។ មួយវិញទៀត ចៅក្រមស៊ើបសួរមានឯករាជ្យភាពក្នុងការស្រាវជ្រាវទៅលើសំណុំរឿងព្រហ្មទណ្ឌដែលខ្លួនទទួលបន្ទុក ធ្វើយ៉ាងណាលាតត្រដាងនូវការពិតនៃសំណុំរឿង តាមរយៈការស៊ើបអង្កេតទៅលើភស្តុតាងដែលមានស្រាប់ ក៏ដូចជាតម្រុយនានាដែលអាចចាត់ឱ្យអ្នកជំនាញដែលសមត្ថកិច្ចធ្វើការស្រាវជ្រាវបន្ថែម ដោយមិនទទួលរងនូវសម្ពាធពីភាគីណាមួយនៅក្នុងសំណុំរឿងនោះឡើយ។

**គ. វិសមិតភាពមុខងារ**

វិសមិតភាព សំដៅទៅលើភាពដែលមិនអាចមាន ឬមិនអាចធ្វើការចូលគ្នាបាន អលទ្ធភាពតាមគន្លងច្បាប់ដែលមិនអាចឱ្យមនុស្សម្នាក់បំពេញមុខងារពីរកន្លែងបាន។ រវាងមុខងារជាចៅក្រម និងមុខងារជាព្រះរាជអាជ្ញា ឬជាព្រះរាជអាជ្ញារងនោះ គឺមានវិសមិតភាពនឹងគ្នាយ៉ាងដាច់ខាត។ ចៅក្រមណាដែលបានបំពេញមុខងារក្នុងឋានៈជាព្រះរាជអាជ្ញា ជាព្រះរាជអាជ្ញារង ឬជាចៅក្រមស៊ើបសួរលើរឿងណាមួយ មិនអាចចូលរួមក្នុងការជំនុំជម្រះរឿងនោះបានទេ បើពុំដូច្នោះទេ សាលក្រមនឹងត្រូវទុកជាមោឃៈ។[6] ចៅក្រមអាចត្រូវបានតែងតាំងជាព្រះរាជអាជ្ញា ហើយព្រះរាជអាជ្ញាក៏អាចត្រូវបានតែងតាំងជាចៅក្រមវិញបានដែរ។[7]

នៅក្នុងរឿងក្តីព្រហ្មទណ្ឌមួយ ប្រសិនបើព្រះរាជអាជ្ញាមួយរូបបានធ្វើការចោទប្រកាន់នៅក្នុងរឿងក្តីនោះហើយ បន្ទាប់មកព្រះរាជអាជ្ញារូបនោះត្រូវបានតែងតាំងជាចៅក្រមវិញ ដូច្នេះគាត់មិនអាចក្លាយទៅជាចៅក្រមស៊ើបសួរក្នុងសំណុំរឿងដែលគាត់ធ្លាប់បានចោទប្រកាន់នោះទេ។ ដូចគ្នាដែរ ប្រសិនបើចៅក្រមស៊ើបសួរដែលធ្លាប់ទទួលបន្ទុកក្នុងការស៊ើបសួរលើសំណុំរឿងមួយ គាត់ក៏មិនអាចក្លាយទៅជាចៅក្រមជំនុំជម្រះនៃសំណុំរឿងដែលគាត់ធ្លាប់ស៊ើបសួរនោះដែរ។ ប្រសិនបើមានករណីបែបនេះណាមួយកើតឡើង នោះសាលក្រមនៃសំណុំរឿងនេះនឹងត្រូវទុកជាមោឃៈ។

**ឃ. សមត្ថកិច្ចដែនដី**

នៅតាមបណ្តារាជធានី-ខេត្ត សុទ្ធតែមានសាលាដំបូងរៀងៗខ្លួន ដោយសាលាដំបូងនីមួយៗ ទទួលភារកិច្ចក្នុងការដោះស្រាយនូវសំណុំរឿង ក៏ដូចជាបទល្មើសព្រហ្មទណ្ឌនានាដែលកើតមាននៅក្នុងដែនសមត្ថកិច្ច

[6] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ២៨៨។
[7] ច្បាប់ស្តីពីលក្ខន្តិកៈ នៃចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤, មាត្រា ៥។

របស់ខ្លួន។ ចៅក្រមដែលបំពេញការងារនៅតាមបណ្តាសាលាដំបូងរាជធានី-ខេត្ត ក៏ត្រូវបានកំណត់នូវដែនសមត្ថកិច្ចរបស់ខ្លួនផងដែរ។

ចៅក្រមដែលមានសមត្ថកិច្ចគឺ៖

- ចៅក្រមស៊ើបសួរនាទីកន្លែងបទល្មើស
- ចៅក្រមស៊ើបសួរនាទីលំនៅឋានឬទីសំណាក់របស់បុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស
- ចៅក្រមស៊ើបសួរនាទីកន្លែងចាប់ខ្លួនបុគ្គលដែលសង្ស័យថា បានប្រព្រឹត្តបទល្មើស។[8]

នៅក្នុងករណីដែលមានពាក្យបណ្តឹងច្រើនទាក់ទងទៅនឹងរឿងក្តីព្រហ្មទណ្ឌតែមួយ តែបានប្តឹងនៅសាលាដំបូងខុសៗគ្នា នោះធ្វើឱ្យមានការពិបាកក្នុងការកំណត់អំពីដែនសមត្ថកិច្ចក្នុងការស៊ើបសួរ ដូច្នេះបញ្ហានេះនឹងត្រូវបានបញ្ជូនទៅប្រធានសភាស៊ើបសួរដើម្បីធ្វើការសម្រេចអំពីសមត្ថកិច្ចដែនដី។ ហើយប្រសិនបើបញ្ហានេះមិនអាចដោះស្រាយបាននៅសភាស៊ើបសួរទេ វិវាទនឹងត្រូវសម្រេចដោយប្រធានតុលាការកំពូល។ ចំពោះការសម្រេចរបស់តុលាការកំពូលទាក់ទងទៅនឹងវិវាទនេះ ជាការសម្រេចបិទផ្លូវតវ៉ា។

## ផ្នែកទី២៖ ការបើកការស៊ើបសួរ និងការប្តឹងទៅចៅក្រមស៊ើបសួរ

ការស៊ើបសួរត្រូវតែធ្វើដោយខានមិនបានចំពោះបទឧក្រិដ្ឋ។ ចំពោះបទមជ្ឈិម ការស៊ើបសួរអាចធ្វើក៏បាន ឬ មិនធ្វើក៏បាន។[9]

### កថាខណ្ឌទី១៖ បែបបទនៃបណ្តឹង

ដំណាក់កាលនៃការស៊ើបសួរអាចកើតឡើងលុះត្រាតែមានបណ្តឹង ដែលបណ្តឹងនោះអាចជាដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ឬបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

#### ក. សេចក្តីសន្និដ្ឋានឱ្យបើកការស៊ើបសួររបស់អយ្យការ

នៅក្នុងរឿងក្តីព្រហ្មទណ្ឌ ដំណាក់កាលស៊ើបសួរគឺជាដំណាក់កាលបន្ទាប់ពីដំណាក់កាលចោទប្រកាន់ដោយតំណាងអយ្យការ។ តំណាងអយ្យការ គឺជាបុគ្គលដែលតំណាងឱ្យអង្គការអយ្យការ ដោយរួមមានព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានី-ខេត្ត។

ការស៊ើបសួរត្រូវបានបើកតាមដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ដែលត្រូវប្តឹងទៅចៅក្រមស៊ើបសួរ។ ការស៊ើបសួរអាចបើកប្រឆាំងលើបុគ្គលម្នាក់ ឬច្រើននាក់ ដោយមានចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងទៅលើអញ្ញាតជន។

ដីកាបញ្ជូនរឿងឱ្យស៊ើបសួររួមមាន៖

---

[8] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១២៣។

[9] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១២២។

- សេចក្ដីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស
- ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន។

ដីកាបញ្ជូនរឿងឱ្យស៊ើបសួរត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា។ ទម្រង់ការនេះមានលក្ខណៈដាច់ខាតត្រូវតែគោរព បើពុំដូច្នេះទេ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរនេះត្រូវទុកជាមោឃៈ។[10]

**ខ. បណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី**

ចៅក្រមស៊ើបសួរ អាចទទួលពាក្យបណ្ដឹង ដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី[11] ដែលធ្វើឡើងដោយជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម នៅក្នុងរឿងក្ដីព្រហ្មទណ្ឌ។

ចៅក្រមស៊ើបសួរធ្វើការកត់សម្គាល់ នូវការដាក់ពាក្យបណ្ដឹង ដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីតាមដីកា។ ចៅក្រមស៊ើបសួរបញ្ជូនបណ្ដឹងនេះទៅព្រះរាជអាជ្ញា។ ក្រោយពីបានឃើញពាក្យប្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ព្រះរាជអាជ្ញាត្រូវប្ដឹងទៅចៅក្រមស៊ើបសួរ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះ អាចធ្វើប្រឆាំងនឹងអញ្ញាតជន ទោះបីជាបណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចោទទៅលើឈ្មោះបុគ្គលម្នាក់ ឬច្រើននាក់ក៏ដោយ។[12]

ព្រះរាជអាជ្ញាអាចសុំកុំឱ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរ ដោយផ្អែកទៅលើការរលត់បណ្ដឹងអាជ្ញា ឬដោយសារអំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌ។ ប្រសិនបើចៅក្រមស៊ើបសួរសម្រេចមិនធ្វើការស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចមួយដោយមានសំអាងហេតុ ព្រមទាំងធ្វើការជូនដំណឹងទៅដើមបណ្ដឹងរដ្ឋប្បវេណី។ ប៉ុន្តែក្នុងករណីដែលចៅក្រមស៊ើបសួរសម្រេចធ្វើការស៊ើបសួរ ដូច្នេះចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ដើម្បីធ្វើការជូនដំណឹងដល់ព្រះរាជអាជ្ញាជាបន្ទាន់។

ដើម្បីការពារកុំឱ្យមានការប្ដឹងដោយបំពាន ឬអូសបន្លាយពេលវេលា ចៅក្រមស៊ើបសួរអាចធ្វើការកំណត់ឱ្យដើមបណ្ដឹងរដ្ឋប្បវេណីបង់ប្រាក់តម្កល់ទុក។ ការបង់ប្រាក់តម្កល់ទុក គឺផ្អែកទៅលើធនធាននៃដើមបណ្ដឹងរដ្ឋប្បវេណី និងទៅលើការលំបាកនៃរឿងដែលអាចមើលឃើញជាមុន ចៅក្រមស៊ើបសួរកំណត់តាមដីកាសម្រេចនូវចំនួនទឹកប្រាក់ដែលដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបង់ ព្រមទាំងរយៈពេលដែលត្រូវបង់ប្រាក់នេះផង។[13] ប្រសិនបើ

---

[10] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ៤៥។
[11] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១២៥។
[12] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៣៩។
[13] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៤០។

ដើមបណ្ដឹងរដ្ឋប្បវេណីពុំមានលទ្ធភាពក្នុងការបង់នូវប្រាក់តម្កល់ដែលកំណត់ដោយចៅក្រមស៊ើបសួរទេ ចៅក្រមស៊ើបសួរអាចធ្វើការលើកលែង ចំពោះការបង់ប្រាក់តម្កល់នេះបាន។ ប្រាក់តម្កល់នឹងត្រូវបានបង្វិលទៅដើមបណ្ដឹងរដ្ឋប្បវេណីវិញនៅពេលដែលនីតិវិធីត្រូវបានបញ្ចប់។ ផ្ទុយទៅវិញ ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថានីតិវិធីធ្វើឡើងដោយបំពាន ឬដោយអូសបន្លាយពេលវេលា នោះចៅក្រមស៊ើបសួរ អាចសម្រេចតាមដីកាសម្រេចឱ្យដើមបណ្ដឹងបង់ប្រាក់ពិន័យរដ្ឋប្បវេណី។ ចំនួនប្រាក់ពិន័យមិនអាចលើសចំនួនទឹកប្រាក់តម្កល់ទុកឡើយ។ ដីកាសម្រេចឱ្យបង់ប្រាក់ពិន័យនេះត្រូវឱ្យដំណឹងដល់សាមីខ្លួនជាបន្ទាន់។[14]

**កថាខណ្ឌទី២៖ អានុភាពនៃបណ្ដឹង**

អយ្យការធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។[15] ការចោទប្រកាន់ដែលធ្វើឡើងដោយតំណាងអយ្យការ ក្នុងការបើកឱ្យមានការស៊ើបសួរ គឺធ្វើឡើងតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលនៅក្នុងដីកាបានចែងអំពីការចោទប្រកាន់ ព្រមទាំងបទល្មើសដែលត្រូវចោទទៅលើបុគ្គលណាមួយនៅក្នុងសេចក្ដីសន្និដ្ឋាន។

**ក. ភាពមិនអាចដកបណ្ដឹងបាន**

ព្រះរាជអាជ្ញាថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យបណ្ដឹង និងពាក្យបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក។ ព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ។ មុននឹងសម្រេច ព្រះរាជអាជ្ញាបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែម។[16] ក្នុងករណីដែលព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ព្រះរាជអាជ្ញានឹងធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលនាំឱ្យកើតមាននូវបណ្ដឹងអាជ្ញា។ នៅពេលដែលបណ្ដឹងអាជ្ញាបានទៅដល់ចៅក្រមស៊ើបសួរហើយ ពាក្យបណ្ដឹងមិនអាចដកវិញបានទេ។ ព្រះរាជអាជ្ញាលែងមានសិទ្ធិក្នុងការចាត់ការ ឬបញ្ជាមន្ត្រីនគរបាលយុត្តិធម៌ឱ្យធ្វើការស៊ើបអង្កេតទៅលើបទល្មើសនោះទៀតដែរ ដោយធ្វើយ៉ាងណារក្សានូវវិសាលភាពនៃបណ្ដឹងក្នុងការស៊ើបសួររបស់ចៅក្រមស៊ើបសួរ។ មួយវិញទៀត សេចក្ដីសន្និដ្ឋានដែលព្រះរាជអាជ្ញាបានធ្វើឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលបញ្ជូនមកដល់ចៅក្រមស៊ើបសួរនោះមិនអាចធ្វើការបន្ថែមទៅលើសេចក្ដីសន្និដ្ឋាននោះទៀតទេ។

[14] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៤១។

[15] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ៤។

[16] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ៤០។

**ខ. ភាតព្វកិច្ចស៊ើបសួរ**

នៅពេលដែលចៅក្រមស៊ើបសួរទទួលបានពាក្យបណ្តឹង ចៅក្រមរូបនោះត្រូវតែធ្វើការស៊ើបសួរទៅលើសំណុំរឿងនោះ។ ពោលគឺ ចៅក្រមស៊ើបសួរមិនអាចច្រានចោល ក្នុងការមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដោយសំអាងថារឿងនោះពុំមានប្រយោជន៍ ដោយធ្លាប់ឆ្លងកាត់ការស៊ើបសួររួចហើយម្តង ឬសំណុំរឿងមិនអាចមានលទ្ធផលក្នុងការស៊ើបសួរ។ ប៉ុន្តែចៅក្រមស៊ើបសួរ អាចមើលទៅលើសមត្ថកិច្ចដែនដី និងសមត្ថកិច្ចសម្ភារៈ។

**គ. វិសាលភាពនៃការថ្កើង**

ចៅក្រមស៊ើបសួរទទួលបណ្តឹងអំពីអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរត្រូវស៊ើបសួរតែអំពីអង្គហេតុនោះប៉ុណ្ណោះ។

ប្រសិនបើមានលេចចេញអង្គហេតុថ្មី ដែលអាចជាបទល្មើសព្រហ្មទណ្ឌ នៅក្នុងពេលស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានអំពីអង្គហេតុនេះទៅព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាអាចប្តឹងសុំឱ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនេះ តាមដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ បើគ្មានដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ ចៅក្រមស៊ើបសួរគ្មានអំណាចស៊ើបសួរអំពីអង្គហេតុថ្មីនោះឡើយ។ ប៉ុន្តែ ចៅក្រមស៊ើបសួរមិនចាំបាច់សុំដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ ប្រសិនបើអង្គហេតុថ្មីនោះ ជាស្ថានទម្ងន់ទោសទៅលើអង្គហេតុ ដែលចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដំបូង។[17]

បន្ទាប់ពីសិក្សាអំពីទំនាក់ទំនងចៅក្រមស៊ើបសួរ និងកិច្ចស៊ើបសួររួចមក ជាបន្តទៀតយើងនឹងសិក្សាអំពីដំណើរការស៊ើបសួររបស់ចៅក្រមស៊ើបសួរ ដោយរួមមាន វិធីសាស្ត្រស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ (ផ្នែកទី១) និងការស្នើសុំបំពេញកិច្ច (ផ្នែកទី២)។

[17] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១២៥។

# ជំពូកទី២
# ដំណើរការស៊ើបសួររបស់ចៅក្រមស៊ើបសួរ

## ផ្នែកទី១៖ វិធីសាស្ត្រស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ

### កថាខណ្ឌទី១៖ ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ

នៅក្នុងដំណើរការនៃការស៊ើបសួរ ចៅក្រមស៊ើបសួរអាចធ្វើការស្រាវជ្រាវដូចជា ការជូនដំណឹងអំពីការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ ការសួរចម្លើយជនត្រូវចោទ ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ការស្តាប់ចម្លើយសាក្សី ការឆែកឆេរនិងចាប់យកវត្ថុតាង ការធ្វើកោសលវិច័យ ការស្តាប់ទូរស័ព្ទ និងដីកាចាត់ឱ្យស៊ើបសួរជំនួស។

#### ក. ការជូនដំណឹងអំពីការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ

ចំពោះបទល្មើសជាក់ស្តែង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែលធ្វើឡើងដោយតំណាងអយ្យការតែងតែធ្វើឡើងដោយមានបង្ហាញនូវខ្លួនជនសង្ស័យមកភ្លាមៗ លើកលែងតែក្នុងបទល្មើសមិនជាក់ស្តែងទើបមិនមានវត្តមានរបស់ជនសង្ស័យមកជាមួយនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នៅចំពោះមុខចៅក្រមស៊ើបសួរ។ ក្រោយពីទទួលបានសំណុំរឿង ព្រមទាំងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវចាប់ផ្តើមពិនិត្យទៅលើសំណុំរឿងដោយរួមមានឯកសារ និងភស្តុតាងដែលមានស្រាប់ ដើម្បីសិក្សាពីសំណុំរឿង។

នៅពេលចូលបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរពិនិត្យអត្តសញ្ញាណជនត្រូវចោទ ប្រាប់ជននេះឱ្យបានដឹងរឿងរ៉ាវដែលចោទប្រកាន់ និងប្រាប់អំពីឈ្មោះបទល្មើសដែលកំណត់ដោយច្បាប់។ ចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទថា ខ្លួនអាចឆ្លើយ ឬមិនឆ្លើយបានដោយសេរី។ និទ្ទេសស្តីពីការប្រាប់នេះត្រូវចុះនៅក្នុងកំណត់ហេតុនៅពេលចូលបង្ហាញខ្លួនលើកដំបូង។ ប្រសិនបើជនត្រូវចោទចង់ឆ្លើយនោះ ចៅក្រមស៊ើបសួរត្រូវទទួលចម្លើយនោះភ្លាម។ ចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទ ឱ្យបានដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការជ្រើសរើសមេធាវី ឬក្នុងការសុំឱ្យចាត់តាំងមេធាវីឱ្យខ្លួន ដោយអនុវត្តតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ ជនត្រូវចោទជាអនីតិជនត្រូវតែមានមេធាវីអមជានិច្ច។ បើគ្មានការជ្រើសរើសដោយជនត្រូវចោទទេ មេធាវីត្រូវបានចាត់តាំងនៅក្នុងលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីអំពីលក្ខន្តិកៈមេធាវី។

ក្រោយពីការចូលបង្ហាញខ្លួនលើកទីមួយ ជនត្រូវចោទដែលនៅក្រៅឃុំ ត្រូវប្រកាសប្រាប់ដល់ចៅក្រមស៊ើបសួរអំពីអាសយដ្ឋានរបស់ខ្លួន។ ជនត្រូវចោទនេះត្រូវបានទទួលដំណឹងថា៖

- ខ្លួនត្រូវតែជូនព័ត៌មាន ដល់ចៅក្រមស៊ើបសួរ នៅពេលណាដែលខ្លួនផ្លាស់ប្តូរអាសយដ្ឋាន

- គ្រប់ការឱ្យដំណឹងដែលបានធ្វើឡើងតាមអាសយដ្ឋានចុងក្រោយ ដែលប្រកាសឡើងដោយជនត្រូវចោទនោះ ត្រូវចាត់ទុកថា បានធ្វើឡើងដល់សាមីខ្លួនផ្ទាល់។

ការឱ្យដំណឹងព្រមទាំងការប្រកាសស្តីអំពីការផ្លាស់ប្តូរអាសយដ្ឋាននោះ ត្រូវចុះក្នុងកំណត់ហេតុនៅពេលចូលបង្ហាញខ្លួនលើកដំបូង។[18]

ក្នុងករណីចាំបាច់ចៅក្រមស៊ើបសួរត្រូវហៅរកអ្នកបកប្រែ។ អ្នកបកប្រែត្រូវស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថាខ្លួននឹងជួយដល់តុលាការ និងបកប្រែឱ្យបានត្រឹមត្រូវតាមចម្លើយទាំងឡាយ។ ក្នុងករណីណាក៏ដោយ អ្នកបកប្រែមិនអាចត្រូវជ្រើសរើសក្នុងចំណោមចៅក្រម ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ ភាគី ឬសាក្សីទេ។[19]

**ខ. ការសួរចម្លើយជនត្រូវចោទ**

នៅក្នុងដំណាក់កាលស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវតែធ្វើការសួរចម្លើយជនត្រូវចោទ ទោះបីជាជនត្រូវចោទត្រូវបានសួរចម្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ឬដំណាក់កាលអយ្យការរួចហើយក៏ដោយ។

កាលណាជនត្រូវចោទមានមេធាវីអម ចៅក្រមស៊ើបសួរ ត្រូវកោះហៅមេធាវីយ៉ាងតិចបំផុត ៥(ប្រាំ) ថ្ងៃមុនការសួរចម្លើយ។ ក្នុងចិរវេលានេះ មេធាវីអាចពិនិត្យមើលសំណុំរឿងនៃនីតិវិធី។ ជនត្រូវចោទអាចត្រូវសួរចម្លើយបានតែនៅចំពោះមុខមេធាវីរបស់ខ្លួនប៉ុណ្ណោះ។ ប៉ុន្តែប្រសិនបើមេធាវីដែលត្រូវបានកោះហៅយ៉ាងត្រឹមត្រូវហើយ មិនចូលបង្ហាញខ្លួននៅថ្ងៃ និងម៉ោងកំណត់ទេ ចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទ ដោយគ្មានវត្តមានរបស់មេធាវី។ និទ្ទេសស្តីអំពីអវត្តមាននេះត្រូវចុះនៅក្នុងកំណត់ហេតុសួរចម្លើយជនត្រូវចោទ។ ក្នុងករណីពិសេសចៅក្រមស៊ើបសួរ អាចសួរចម្លើយជនត្រូវចោទ ដោយមិនបាច់កោះហៅមេធាវី ប្រសិនបើជនត្រូវចោទបោះបង់ចោលយ៉ាងជាក់លាក់នូវវត្តមានរបស់មេធាវីខ្លួន។ ការបោះបង់ចោលនេះត្រូវចុះនៅក្នុងកំណត់ហេតុមួយផ្សេងពីកំណត់ហេតុសួរចម្លើយ និងត្រូវចុះហត្ថលេខាដោយជនត្រូវចោទ។ ក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរក៏អាចធ្វើការសួរចម្លើយដោយមិនបាច់កោះហៅមេធាវីបានដែរ។ ភាពបន្ទាន់នេះត្រូវតែបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬបណ្តាលមកពីការភ័យខ្លាចបាត់បង់តម្រុយនៃភស្តុតាង។ ប្រភេទនៃភាពបន្ទាន់ ត្រូវតែចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។[20]

---

[18] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៤៣។

[19] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៤៤។

[20] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា១៤៥។

នៅពេលសួរចម្លើយជនត្រូវចោទ ព្រះរាជអាជ្ញា និងមេធាវីក៏អាចលើកសំណួរបានដែរ ដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។ ក្នុងករណីមិនអនុញ្ញាត ករណីនោះត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។[21]

កាលណាចិរវេលា ៤ (បួន) ខែ បានកន្លងផុតទៅ ចាប់ពីពេលសួរចម្លើយនៅពេលបង្ហាញខ្លួនលើកដំបូង ជនត្រូវចោទមិនត្រូវបានសួរចម្លើយ ឬសួរតទល់ទេ ចៅក្រមស៊ើបសួរត្រូវតែទទួលចម្លើយ ប្រសិនបើជនត្រូវចោទបានស្នើសុំ។ បើចៅក្រមស៊ើបសួរមិនព្រមកោះហៅជនត្រូវចោទក្នុងចិរវេលា ១ (មួយ) ខែ បន្ទាប់ពីការសុំទេ នោះជនត្រូវចោទអាចប្ដឹងផ្ទាល់ទៅសភាស៊ើបសួរដែលទទួលចម្លើយនេះដោយខ្លួនឯង។ បន្ទាប់មកកំណត់ហេតុត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ។[22]

មេធាវីរបស់ជនត្រូវចោទដែលជាប់ឃុំ អាចប្រាស្រ័យទាក់ទងដោយសេរីជាមួយកូនក្ដីរបស់ខ្លួននៅក្នុងពន្ធនាគារ ឬនៅក្នុងមណ្ឌលឃុំខ្លួន។ ការសន្ទនារវាងមេធាវី និងជនត្រូវចោទមិនអាចត្រូវគេស្ដាប់ ឬថតបានទេ។ មេធាវីអាចអានលិខិតនៃសំណុំរឿងឱ្យកូនក្ដីខ្លួនស្ដាប់។ ផ្ទុយទៅវិញមេធាវីមិនអាចឱ្យលិខិតថតចម្លងពីលិខិតនៃសំណុំរឿង ដល់កូនក្ដីរបស់ខ្លួនបានឡើយ។[23]

**គ. ការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី**

ក្រោយពីចៅក្រមស៊ើបសួរធ្វើការសួរចម្លើយជនត្រូវចោទរួចមក ប្រសិនបើសំណុំរឿងព្រហ្មទណ្ឌនោះមានដើមបណ្ដឹងរដ្ឋប្បវេណី នោះចៅក្រមស៊ើបសួរត្រូវធ្វើលិខិតអញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណី ដោយធ្វើឡើងជាលាយលក្ខណ៍អក្សរ ប្រសិនបើចៅក្រមស៊ើបសួរទទួលបានពាក្យការពារក្ដីដែលធ្វើឡើងដោយមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង នោះចៅក្រមស៊ើបសួរត្រូវកោះហៅមេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីយ៉ាងតិចបំផុត ៥ (ប្រាំ) ថ្ងៃ មុនការស្ដាប់ចម្លើយអមជាមួយនឹងដើមបណ្ដឹងរដ្ឋប្បវេណី។ នៅក្នុងចិរវេលាមុនការស្ដាប់ចម្លើយមេធាវីដើមបណ្ដឹងអាចពិនិត្យសំណុំរឿងនៃនីតិវិធីបាន។

ដើមបណ្ដឹងរដ្ឋប្បវេណី អាចត្រូវបានគេស្ដាប់ចម្លើយតែនៅចំពោះមុខមេធាវីរបស់ខ្លួនប៉ុណ្ណោះ។ ប៉ុន្តែប្រសិនបើមេធាវីដែលត្រូវបានកោះហៅយ៉ាងត្រឹមត្រូវ ហើយមិនចូលមកបង្ហាញខ្លួននៅថ្ងៃ និងម៉ោងតាមកំណត់ទេ ចៅក្រមស៊ើបសួរអាចស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីដោយគ្មានវត្តមានរបស់មេធាវី។ និទ្ទេសស្ដីពីអវត្តមាន ត្រូវចុះនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយ។ ក្នុងករណីពិសេស ចៅក្រមស៊ើបសួរអាចស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីបាន ដោយមិនបាច់កោះហៅមេធាវី ប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណីបោះបង់ចោលយ៉ាងជាក់

[21] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៤៦។

[22] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៤៨។

[23] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៤៩។

លាក់នូវវត្តមានមេធាវីរបស់ខ្លួន។ ការបោះបង់ចោលនេះត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុមួយដោយឡែកពីកំណត់ហេតុស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី និងត្រូវចុះហត្ថលេខាដោយដើមបណ្ដឹងរដ្ឋប្បវេណី។ ក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរក៏អាចស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ដោយមិនចាំបាច់កោះហៅមេធាវីបានដែរ។ ភាពបន្ទាន់នេះ ត្រូវបណ្ដាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬបណ្ដាលមកពីភ័យខ្លាចបាត់បង់តម្រុយភស្តុតាង។ ប្រភេទនៃភាពបន្ទាន់ត្រូវតែចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។ ចៅក្រមស៊ើបសួរអាចហៅរកអ្នកបកប្រែបាន។[24]

នៅក្នុងពេលស្ដាប់ចម្លើយ ព្រះរាជអាជ្ញា និងមេធាវីអាចលើកសំណួរមកសួរបាន ដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។ ក្នុងករណីមិនអនុញ្ញាត ករណីនោះត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។[25]

**ឃ. ការស្ដាប់ចម្លើយសាក្សី**

ជនដែលត្រូវបានស្ថិតនៅក្នុងស្ថានភាពដែលបទល្មើសបានកើតឡើង ឬបានឃើញ ព្រមទាំងឮនូវដំណើររឿងដែលទាក់ទងទៅនឹងបទល្មើសសុទ្ធតែអាចក្លាយទៅជាសាក្សីក្នុងសំណុំរឿងបាន។ សាក្សីអាចត្រូវបានស្គាល់តាមរយៈហេតុការណ៍ជាក់ស្ដែង ឬអាចជាបុគ្គលដែលត្រូវបានបង្ហាញដោយជនសង្ស័យ ឬដើមបណ្ដឹងរដ្ឋប្បវេណី។

ចៅក្រមស៊ើបសួរ អាចស្ដាប់ចម្លើយបុគ្គលគ្រប់រូប ដែលចម្លើយនោះអាចមានប្រយោជន៍នៅក្នុងការសម្ដែងឱ្យឃើញការពិត។ ចៅក្រមស៊ើបសួរស្ដាប់ចម្លើយសាក្សីដាច់ពីគ្នា ដោយគ្មានវត្តមានជនត្រូវចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី។ ចៅក្រមស៊ើបសួរក៏អាចសួរតទល់គ្នារវាងជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សីផងបានដែរ។ បុគ្គលគ្រប់រូប ដែលត្រូវបានចៅក្រមស៊ើបសួរកោះហៅក្នុងឋានៈជាសាក្សី ត្រូវតែមកបង្ហាញខ្លួន។ ក្នុងករណីរឹងទទឹង ចៅក្រមស៊ើបសួរអាចសុំឱ្យកងកម្លាំងសាធារណៈបង្ខំសាក្សីនេះឱ្យចូលបង្ហាញខ្លួនបាន។ ចៅក្រមស៊ើបសួរចេញបញ្ជាឱ្យចូលមកបង្ហាញខ្លួន។ បញ្ជានេះត្រូវមានអត្តសញ្ញាណរបស់សាក្សី ហើយត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង។[26]

ប្រសិនបើសាក្សីឈឺ ឬមិនអាចធ្វើដំណើរបាន ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី អាចចុះទៅកាន់លំនៅឋាន ឬទីកន្លែងដែលសាក្សីនោះនៅ ដើម្បីទទួលចម្លើយ។[27]

[24] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៥០។

[25] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៥១។

[26] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៥៣។

[27] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៥៤។

**ខ. ការឆែកឆេរ និងការចាប់យកវត្ថុតាង**

ចៅក្រមស៊ើបសួរអាចធ្វើការឆែកឆេរបាន។ ចៅក្រមស៊ើបសួរត្រូវឆែកឆេរនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេ ត្រូវធ្វើនៅចំពោះមុខសាក្សី ២ (ពីរ) នាក់ ដែលខ្លួនចាត់តាំង។ សាក្សីមិនអាចជានគរបាល ឬជាកងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ។ ចៅក្រមស៊ើបសួរមិនអាចផ្តើមឆែកឆេរមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចបានទេ លើកលែងតែៈ

- ក្នុងករណីឆែកឆេរនៅទីកន្លែងដែលបើកចំហដល់សាធារណជន
- ក្នុងករណីឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ឬប្រើប្រាស់គ្រឿងញៀន។

ក្នុងករណីដែលការឆែកឆេរនៅក្នុងការិយាល័យមេធាវី ត្រូវធ្វើនៅចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវីនោះ។ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុ ស្តីពីការឆែកឆេរដោយមានចុះហត្ថលេខារបស់ខ្លួន និងក្រឡាបញ្ជី រួមជាមួយអ្នកកាន់កាប់ទីកន្លែង ឬសាក្សី ២ (ពីរ) នាក់។ កំណត់ហេតុត្រូវចុះនិទ្ទេសអំពីអត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬសាក្សីនីមួយៗ។ កាលបើការឆែកឆេរប្រព្រឹត្តទៅនៅក្នុងការិយាល័យមេធាវី កំណត់ហេតុត្រូវចុះនិទ្ទេសអំពីវត្តមានរបស់ប្រធានគណៈមេធាវី ឬរបស់ប្រតិភូនៃប្រធានគណៈមេធាវីនេះ។[28]

នៅពេលដែលមិនទាន់ចេញដីកាដំណោះស្រាយរឿងនៅឡើយទេ ចៅក្រមស៊ើបសួរមានសមត្ថភាពប្រគល់សងទៅម្ចាស់ដើមវិញនូវវត្ថុដែលចាប់បាន កាលណាកម្មសិទ្ធិនេះគ្មានការជំទាស់អ្វីប្រាកដប្រជាទេ។ ចៅក្រមស៊ើបសួរសម្រេចតាមដីកាដែលមានសំអាងហេតុ ក្រោយពីបានទទួលមតិពីព្រះរាជអាជ្ញា។ ដីកាសម្រេចត្រូវឱ្យដំណឹងជាបន្ទាន់ដល់អ្នកប្តឹង និងមេធាវីនៃអ្នកប្តឹងប្រសិនបើមាន។ មិនគួរប្រគល់សងឱ្យទៅអ្នកប្តឹងសុំទេ កាលណាវិធានការនេះ អាចបង្កជាឧបសគ្គដល់ការសម្តែងឱ្យឃើញការពិត។ វត្ថុដែលមានគ្រោះថ្នាក់ដល់បុគ្គល ឬទ្រព្យសម្បត្តិដូចជាអាវុធ ឬជាតិផ្ទុះ ព្រមទាំងវត្ថុដែលការកាន់កាប់មិនស្របច្បាប់ មិនអាចត្រូវប្រគល់សងទៅឱ្យសាមីខ្លួនបានទេ។ វត្ថុទាំងនេះត្រូវរឹបអូសជាកម្មសិទ្ធិរបស់រដ្ឋ។[29]

**ច. ការធ្វើកោសលវិច័យ**

នៅក្នុងករណីដែលមានបញ្ហាបច្ចេកទេសចោទឡើង ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យធ្វើកោសលវិច័យដោយឯកឯង ឬតាមពាក្យសុំរបស់ព្រះរាជអាជ្ញា របស់ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី។ កាលណាចៅក្រម

[28] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៥៩។

[29] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៦១។

ស៊ើបសួរបដិសេធមិនព្រមធ្វើតាមពាក្យសុំធ្វើកោសលវិច័យទេ ចៅក្រមស៊ើបសួរត្រូវសម្រេចតាមដីកាដោយមានសំអាងហេតុ។ ដីកាត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ប្រសិនបើពាក្យសុំនោះចេញមកពីព្រះរាជអាជ្ញា និង ១ (មួយ) ខែ ប្រសិនបើពាក្យនោះចេញមកពីជនត្រូវចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណី។ ដីកាសម្រេចនេះត្រូវជូនដំណឹងឱ្យដល់អ្នកប្ដឹងសុំជាបន្ទាន់។[30]

ចៅក្រមស៊ើបសួរ តាមធម្មតាត្រូវជ្រើសរើសអ្នកជំនាញដែលត្រូវបានចុះឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ។ ចៅក្រមស៊ើបសួរ តាមដីកាដោយមានសំអាងហេតុជាពិសេស អាចចាត់តាំងអ្នកជំនាញ ដែលគ្មានឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិបាន។ ក្នុងករណីនេះអ្នកជំនាញត្រូវស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថា ខ្លួននឹងផ្ដល់ជំនួយដោយស្មោះត្រង់ដល់ការស្វែងរកយុត្តិធម៌។[31]

អ្នកជំនាញបំពេញបេសកកម្មរបស់ខ្លួន ក្រោមការពិនិត្យរបស់ចៅក្រមស៊ើបសួរ។ អ្នកជំនាញត្រូវជូនព័ត៌មានដល់ចៅក្រមស៊ើបសួរ អំពីការប្រព្រឹត្តទៅនៃបេសកកម្មរបស់ខ្លួនជាអាទិ៍ ការលំបាកដែលខ្លួនអាចជួបប្រទះ។ ប្រសិនបើអ្នកជំនាញមិនគោរពរយៈពេលដែលកំណត់ដោយចៅក្រមស៊ើបសួរទេ ចៅក្រមស៊ើបសួរចាត់អ្នកជំនាញផ្សេងទៀតជំនួសអ្នកជំនាញនោះ។ ប៉ុន្តែ ប្រសិនបើកាលៈទេសៈតម្រូវនោះ ចៅក្រមស៊ើបសួរអាចអនុញ្ញាតតាមដីកាសម្រេចឱ្យធ្វើការពន្យារពេលបាន។[32]

កាលណារបាយការណ៍កោសលវិច័យត្រូវបានធ្វើរួចហើយ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញា។ របាយការណ៍កោសលវិច័យត្រូវដាក់ចូលក្នុងសំណុំរឿងស៊ើបសួរ។ ចៅក្រមស៊ើបសួរកោះហៅជនត្រូវចោទ និងមេធាវី ដើម្បីប្រាប់ឱ្យដឹងពីសេចក្ដីសន្និដ្ឋាននៃកោសលវិច័យនេះ។ ចៅក្រមស៊ើបសួរអាចកោះហៅដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីផងដែរ ដើម្បីប្រាប់ឱ្យដឹងពីសេចក្ដីសន្និដ្ឋាននៃកោសលវិច័យ។ ចៅក្រមស៊ើបសួរកំណត់រយៈពេលដែលអនុញ្ញាតឱ្យព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណីដាក់ពាក្យសុំធ្វើកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យ។ រយៈពេលនេះមិនអាចតិចជាង ១០ (ដប់) ថ្ងៃទេ។ ក្នុងរយៈពេលនេះ សំណុំរឿងដែលរួមមានរបាយការណ៍កោសលវិច័យ អាចត្រូវបានពិនិត្យដោយមេធាវី។ គ្រប់ពាក្យសុំដីកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យ ត្រូវតែមានសំអាងហេតុនិងធ្វើឡើងជាលាយលក្ខណ៍អក្សរ។ កាលណាចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំធ្វើកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យទេ ចៅក្រមស៊ើបសួរត្រូវសម្រេចតាមដីកាដោយមានសំអាងហេតុ។ ដីកាត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ប្រសិនបើពាក្យសុំចេញ

[30] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៦២។
[31] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៦៤។
[32] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៦៦។

មកពីព្រះរាជអាជ្ញា និង ១ (មួយ) ខែ ប្រសិនបើពាក្យនេះចេញពីជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី។ ដីកាត្រូវឱ្យដំណឹងជាបន្ទាន់ដល់អ្នកប្តឹងសុំ។ គ្រប់ពាក្យសុំធ្វើកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យដែលធ្វើឡើងក្រោយផុតរយៈពេលដែលកំណត់ដោយចៅក្រមស៊ើបសួរ ត្រូវដាក់បញ្ចូលក្នុងសំណុំរឿង។ ប្រសិនបើចៅក្រមស៊ើបសួរដែលបានទទួលពាក្យសុំឱ្យធ្វើកោសលវិច័យ ធ្វើកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យ មិនព្រមសម្រេចក្នុងរយៈពេលដែលបានចែងក្នុងកថាខណ្ឌទី២ នៃមាត្រា១៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ[33] ឬចែងក្នុងមាត្រានេះ អ្នកសុំអាចធ្វើពាក្យប្តឹងដោយផ្ទាល់តាមរយៈពាក្យសុំដល់សភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។[34]

សោហ៊ុយក្នុងការធ្វើកោសលវិច័យជាបន្ទុករបស់អ្នកស្នើសុំ។ កាលណាចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ ស្នើសុំឱ្យធ្វើកោសលវិច័យ កោសលវិច័យបន្ថែម ឬធ្វើប្រតិកោសលវិច័យ សោហ៊ុយទាំងនេះជាបន្ទុករបស់រដ្ឋ។[35]

### ឆ. ការស្តាប់ទូរស័ព្ទ

តាមតម្រូវការចាំបាច់ដើម្បីសម្តែងឱ្យឃើញនូវការពិត ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យស្តាប់ និងថតការសន្ទនាតាមទូរស័ព្ទ។ ចៅក្រមស៊ើបសួរក៏អាចបង្គាប់ឱ្យចាប់ និងថតគ្រប់ការឆ្លើយឆ្លងគ្នា តាមមធ្យោបាយទូរគមនាគមន៍ផងដែរដូចជា សារតាមទូរសារ ឬសារតាមអិនធើណែត។ ចៅក្រមស៊ើបសួរអាចសុំឱ្យគ្រប់អង្គភាពសាធារណៈ ឬគ្រប់មន្ត្រីរាជការជំនាញតាំងឧបករណ៍បច្ចេកទេស និងធ្វើការថត។ ចៅក្រមស៊ើបសួរបញ្ជាក់នៅក្នុងដីកាសម្រេចរបស់ខ្លួនអំពីប្រភេទនៃទំនាក់ទំនងដែលត្រូវចាប់ ព្រមទាំងអំពីរយៈពេលនៃបេសកកម្ម។ អង្គភាពសាធារណៈ មន្ត្រីរាជការដែលចាត់តាំង ត្រូវបំពេញតាមពាក្យសុំរបស់ចៅក្រមស៊ើបសួរ។ នៅក្នុងពេលអនុវត្តបេសកកម្ម អង្គភាពសាធារណៈ ឬគ្រប់មន្ត្រីរាជការដែលចាត់តាំងត្រូវជូនព័ត៌មានដល់ចៅក្រមស៊ើបសួរអំពីការប្រព្រឹត្តទៅនៃបេសកកម្មជាអាទិ៍ អំពីការលំបាកជាយថាហេតុ។ កាលណាបេសកកម្មត្រូវបានបំពេញរួចហើយ អង្គភាពសាធារណៈ ឬគ្រប់មន្ត្រីរាជការនោះត្រូវចម្លងជាលាយលក្ខណ៍អក្សរនូវសំឡេងដែលថតបាន។ ការធ្វើឱ្យទៅជាលាយលក្ខណ៍អក្សរនេះ ត្រូវឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនូវខ្លឹមសារនៃសំឡេងដែលថតបាន។ សំឡេងដែលថតបាននេះត្រូវប្រគល់ជូនចៅក្រមស៊ើបសួរ និងបិទស្លាក។ គ្រប់ពេលវេលា ចៅក្រមស៊ើបសួរអាចចុះទៅកាន់ទីកន្លែងដែលធ្វើការចាប់ និងថតនោះ។ ការចូលទៅក្នុងទីកន្លែងទាំងនេះ មិនអាចត្រូវបានហាមឃាត់ដល់ចៅក្រម

---

[33] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៦២។

[34] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៧០។

[35] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៧១។

ស៊ើបសួរដោយសំអាងលើមូលហេតុអ្វីបានទេ ទោះបីជាកន្លែងឃោធាក៏ដោយ។ ចៅក្រមស៊ើបសួរក៏អាចធ្វើកិច្ចការនេះតាមដីកាចាត់ឱ្យស៊ើបសួរជំនួសបានដែរ។[36]

**ខ. ដីកាចាត់ឱ្យស៊ើបសួរជំនួស**

នៅក្នុងដំណើរការនៃការស៊ើបអង្កេត ប្រសិនបើចៅក្រមស៊ើបសួរជួបប្រទះនូវឧបសគ្គណាមួយទាក់ទងទៅនឹងការស្វែងរកភស្តុតាងក្នុងការបង្ហាញនូវការពិត ចៅក្រមស៊ើបសួរអាចប្រគល់សិទ្ធទៅបុគ្គលដែលមានសមត្ថកិច្ច ដើម្បីធ្វើការស៊ើបសួរជំនួស ដោយចៅក្រមស៊ើបសួរត្រូវចេញដីកាចាត់ឱ្យស៊ើបសួរជំនួស។

តាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស ចៅក្រមស៊ើបសួរអាចប្រគល់សិទ្ធិឱ្យចៅក្រមនៃតុលាការរបស់ខ្លួន ឬតុលាការផ្សេងទៀត មន្ត្រីនគរបាលយុត្តិធម៌ ឬដល់អង្គភាពនគរបាលយុត្តិធម៌ ដើម្បីបំពេញកិច្ចស៊ើបសួរ។[37] ដីកាចាត់ឱ្យស៊ើបសួរជំនួសបញ្ជាក់អំពីប្រភេទនៃកិច្ចដែលត្រូវធ្វើ។ កិច្ចនោះត្រូវតែមានទំនាក់ទំនងដោយផ្ទាល់ជាមួយបទល្មើសដែលចោទប្រកាន់។ ដីកាចាត់ឱ្យស៊ើបសួរជំនួសមិនអាចមានលក្ខណៈជាទូទៅទេ ត្រូវណែនាំឱ្យបានច្បាស់លាស់។ ចៅក្រមស៊ើបសួរកំណត់ថិរវេលាដែលត្រូវអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស។ ដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវមានចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង។[38]

**កថាខណ្ឌទី២៖ ការស្នើសុំបំពេញកិច្ច**

ការស្នើសុំបំពេញកិច្ចអាចធ្វើឡើងតាមរយៈ ការស្នើសុំបំពេញកិច្ចដោយព្រះរាជអាជ្ញា ការស្នើសុំបំពេញកិច្ចដោយដើមបណ្តឹងរដ្ឋប្បវេណី និងការស្នើសុំបំពេញកិច្ចដោយជនត្រូវចោទ។

**ក. ព្រះរាជអាជ្ញា**

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ព្រះរាជអាជ្ញាអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍។ ប្រសិនបើចៅក្រមស៊ើបសួរ មិនព្រមធ្វើតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាទេ នោះចៅក្រមរូបនេះត្រូវចេញដីកាបដិសេធនៅក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ។ ដីកានេះត្រូវមានសំអាងហេតុ ហើយត្រូវតែជូនដំណឹងដល់ព្រះរាជអាជ្ញាក្នុងថិរវេលាយ៉ាងឆាប់បំផុត។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្តឹងដោយផ្ទាល់តាមរយៈពាក្យសុំទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។[39]

---

[36] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៧២។

[37] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៧៣។

[38] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៧៤។

[39] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៣២។

**ខ. ដើមបណ្តឹងរដ្ឋប្បវេណី**

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ដើមបណ្តឹងរដ្ឋប្បវេណីអាចសុំដល់ចៅក្រមស៊ើបសួរឱ្យស្តាប់ចម្លើយខ្លួន ស្តាប់ចម្លើយសាក្សី សួរចម្លើយជនត្រូវចោទ សួរតទល់គ្នា ឬចុះទៅដល់ទីកន្លែង។ ពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។ ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំនេះទេ ចៅក្រមរូបនេះត្រូវចេញដីកាបដិសេធក្នុងចិរវេលា ១ (មួយ) ខែ ក្រោយពេលទទួលពាក្យសុំ។ ដីកានេះត្រូវតែមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងដល់ដើមបណ្តឹងរដ្ឋប្បវេណី។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងចិរវេលា ១ (មួយ) ខែទេ ដើមបណ្តឹងរដ្ឋប្បវេណី អាចប្តឹងដោយផ្ទាល់តាមរយៈពាក្យសុំដល់សភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។[40]

**គ. ជនត្រូវចោទ**

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ជនត្រូវចោទអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើការសួរចម្លើយខ្លួន ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សី សួរតទល់គ្នា ឬចុះទៅដល់ទីកន្លែង។ ពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវមានសំអាងហេតុ។ ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំនេះទេ ចៅក្រមរូបនេះត្រូវចេញដីកាបដិសេធនៅក្នុងចិរវេលា ១ (មួយ) ខែ បន្ទាប់ពីពេលទទួលពាក្យសុំ។ ដីកានេះត្រូវតែមានសំអាងហេតុ និងត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងចិរវេលា ១ (មួយ) ខែទេ ជនត្រូវចោទអាចប្តឹងដោយផ្ទាល់ តាមរយៈពាក្យសុំដល់សភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។[41]

## ផ្នែកទី២៖ វិធានការនិរន្តរាយ

និរន្តរាយ មានន័យថា ការមិនមានអន្តរាយ ដំណើរដែលគ្មានគ្រោះថ្នាក់។[42] វិធានការនេះសំដៅដល់ការចេញដីកាឱ្យចូលខ្លួន ដីកាឱ្យនាំខ្លួន ដីកាឱ្យចាប់ខ្លួន ដីកាឱ្យឃុំខ្លួន និងការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យតាមផ្លូវតុលាការដោយចៅក្រមស៊ើបសួរ។ ដើម្បីធានាដល់កិច្ចស៊ើបសួរឱ្យមានប្រសិទ្ធភាព ក្រមនីតិវិធីព្រហ្មទណ្ឌបានប្រគល់អំណាចក្នុងការចាប់បង្ខំតាមនីតិវិធី ឬតាមវិធានការនិរន្តរាយទៅដល់ចៅក្រមស៊ើបសួរ។ ដោយឡែកផ្អែកទៅលើមូលដ្ឋានគ្រឹះនៃការចាត់ការតាមវិធានការនិរន្តរាយ ចៅក្រមស៊ើបសួរមានអំណាចចេញនូវដីកាជាច្រើនដើម្បីស្តែងឡើងពីសកម្មភាពរបស់ខ្លួន។ ជាគោលការណ៍នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីងាយស្រួលក្នុងការ

---

[40] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៣៤។

[41] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៣៣។

[42] យោងតាមវចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត

ស៊ើបអង្កេតស្វែងរកភស្តុតាងពិតប្រាកដ សម្រាប់ដាក់បន្ទុក ឬដោះបន្ទុកទៅដល់ចៅក្រមស៊ើបសួរក្នុងរឿងក្តីព្រហ្មទណ្ឌ។

កាលណាបុគ្គលណាម្នាក់ពុំឆ្លើយតបនឹងការកោះហៅ ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យចូលខ្លួន ដើម្បីឱ្យសាមីខ្លួនចូលមកបង្ហាញខ្លួន។ នៅក្នុងដំណាក់កាលនៃការបំពេញកិច្ចស៊ើបសួរនេះ ចៅក្រមស៊ើបសួរមានអំណាចចេញដីកា បង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំខ្លួន ដីកាបង្គាប់ឱ្យចាប់ខ្លួន និងដីកាបង្គាប់ឱ្យឃុំខ្លួនដល់បុគ្គលណាម្នាក់ ឬច្រើននាក់ ឬដល់ជនត្រូវចោទ ឬលើបុគ្គលដែលមានតម្រុយពិរុទ្ធភាព ដើម្បីឱ្យចូលបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ។[43]

**កថាខណ្ឌទី១៖ ដីកាបង្គាប់ឱ្យចូលខ្លួន**

ដីកាបង្គាប់ឱ្យចូលខ្លួន ត្រូវជូនដំណឹងដល់បុគ្គលដែលពាក់ព័ន្ធ ដោយមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬដោយអាជ្ញាសាលា។ បុគ្គលដែលពាក់ព័ន្ធទទួលចុងដីកា ហើយត្រូវចុះហត្ថលេខានៅលើដើមដីកា ដែលត្រូវបង្វិលជូនចៅក្រមស៊ើបសួរវិញ។ មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬអាជ្ញាសាលាត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរ ប្រសិនបើមានការលំបាកក្នុងការអនុវត្តបេសកកម្មរបស់ខ្លួន។[44]

ដីកាបង្គាប់ឱ្យចូលខ្លួនត្រូវមានចុះអត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស និងថ្ងៃ ខែ ឆ្នាំ ម៉ោង និងទីកន្លែងដែលត្រូវចូលបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ។ ចៅក្រមដែលចេញដីកាត្រូវសរសេរឈ្មោះ ឋានៈរបស់ខ្លួន និងបោះត្រា។[45]

ការចេញដីកាបង្គាប់ឱ្យចូលខ្លួននេះ គឺជាការកោះហៅបុគ្គលទាំងឡាយដែលពាក់ព័ន្ធក្នុងបទល្មើសដើម្បីឱ្យផ្តល់ចម្លើយ ឬវត្ថុតាងផ្សេងៗ ដែលចៅក្រមស៊ើបសួរចង់ដឹង ឬចង់បាន និងប្រាប់អំពីពិរុទ្ធភាពរបស់ខ្លួន។

**កថាខណ្ឌទី២៖ ដីកាបង្គាប់ឱ្យនាំខ្លួន**

ដីកាបង្គាប់ឱ្យនាំខ្លួន គឺជាបញ្ជាដល់កងកម្លាំងសាធារណៈឱ្យចាប់ និងនាំខ្លួនបុគ្គលណាម្នាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ។ ដីកាបង្គាប់ឱ្យនាំខ្លួន អាចត្រូវចេញទៅលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព។[46]

ការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ត្រូវប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌។ ក្នុងករណីបន្ទាន់ ដីកាបង្គាប់ឱ្យនាំខ្លួន ត្រូវផ្សព្វផ្សាយដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ។ ដើមដីកានេះ ត្រូវប្រគល់

[43] សុខ រឿន, មេរៀននីតិវិធីព្រហ្មទណ្ឌ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ទំព័រ៤៣។

[44] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៨៨។

[45] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា១៨៧។

[46] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា១៩០។

ជូនជាបន្ទាន់ដល់មន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលបន្ទុកអនុវត្តដីកានោះ។ នៅពេលអនុវត្តដីកានេះ មន្ត្រីនគរបាលយុត្តិធម៌មិនអាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចបានទេ។ ក្នុងករណីមានការលំបាកក្នុងការអនុវត្តបេសកកម្មរបស់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរ។[47]

ប្រសិនបើដោយមូលហេតុនៃកាលៈទេសៈ បុគ្គលដែលពាក់ព័ន្ធមិនអាចត្រូវនាំខ្លួនទៅបង្ហាញខ្លួនដល់ចៅក្រមស៊ើបសួរក្រោយពេលចាប់ខ្លួនបានទេ បុគ្គលនេះត្រូវតែនាំខ្លួនទៅក្នុងអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ក្នុងមណ្ឌលឃុំខ្លួន ឬនៅក្នុងពន្ធនាគារ។ បុគ្គលនេះត្រូវតែនាំខ្លួនទៅបង្ហាញខ្លួនយ៉ាងយូរបំផុតនៅថ្ងៃបន្ទាប់ដល់ចៅក្រមស៊ើបសួរ ឬដល់អ្នកជំនួស។ ប្រសិនបើការបង្ហាញខ្លួនមិនបានប្រព្រឹត្តទៅនៅថ្ងៃបន្ទាប់ទេ បុគ្គលពាក់ព័ន្ធត្រូវបានដោះលែងឱ្យមានសេរីភាពវិញ។[48] កាលណាបុគ្គលណាម្នាក់ដែលត្រូវបានគេចាប់ខ្លួនដោយអនុវត្តតាមដីកាបង្គាប់ឱ្យនាំខ្លួនត្រូវបានឃុំខ្លួន នោះថិរវេលានៃការឃុំខ្លួននេះ ត្រូវរាប់បញ្ចូលទៅក្នុងថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ប្រសិនបើមាន។[49] ដីកាបង្គាប់ឱ្យនាំខ្លួននេះ កើតមានឡើងនៅពេលដែលបុគ្គល ដែលត្រូវបានចេញដីកាបង្គាប់ឱ្យចូលខ្លួន ហើយមិនព្រមចូលបង្ហាញខ្លួនតាមដីការបស់ចៅក្រមស៊ើបសួរ។

**កថាខណ្ឌទី៣៖ ដីកាបង្គាប់ឱ្យចាប់ខ្លួន**

ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួនទៅលើជនត្រូវចោទ ឬបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព។ ចៅក្រមស៊ើបសួរនឹងអាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួនបានលុះត្រាតែ បទល្មើសដែលចោទប្រកាន់ ជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ ព្រមទាំងបុគ្គលដែលពាក់ព័ន្ធ បានគេចខ្លួនមិនដឹងជាស្ថិតនៅទីកន្លែងណា ឬស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ដីកាបង្គាប់ឱ្យចាប់ខ្លួន គឺជាបញ្ជាដល់កងកម្លាំងសាធារណៈឱ្យស្រាវជ្រាវរកចាប់ និងឱ្យនាំខ្លួនបុគ្គលនោះ ទៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។ នៅពេលចាប់ ឬនាំខ្លួនបុគ្គលនោះបានហើយ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួល និងឃុំខ្លួនបុគ្គលនោះ។[50] មុននឹងចេញដីកាបង្គាប់ឱ្យចាប់ខ្លួន ចៅក្រមស៊ើបសួរត្រូវតែទទួលយោបល់ពីព្រះរាជអាជ្ញា ហើយចៅក្រមស៊ើបសួរត្រូវចេញដីកាដោយមានចែងមូលហេតុ ក្រោយពីបានទទួលយោបល់ពីព្រះរាជអាជ្ញា។

[47] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា១៩២។
[48] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា១៩៣។
[49] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា១៩៤។
[50] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា១៩៦។

ការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌។ ក្នុងករណីបន្ទាន់ ដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវផ្សព្វផ្សាយទៅតាមអង្គភាពនគរបាល ឬកងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ។ ដើមដីកាត្រូវប្រគល់ក្នុងរយៈពេលយ៉ាងខ្លីបំផុតឱ្យដល់មន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលបន្ទុកអនុវត្តដីកានោះ។ មន្ត្រីនគរបាលយុត្តិធម៌ មិនអាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចបានទេ។ ប្រសិនបើមានការលំបាកក្នុងអនុវត្តបេសកកម្មរបស់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរ។[51]

ការបង្ហាញខ្លួនតាមដីកាបង្គាប់ឱ្យចាប់ខ្លួន ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ត្រូវតែទទួល និងឃុំខ្លួនជនត្រូវចោទដែលជាកម្មវត្ថុនៃដីកាបង្គាប់ឱ្យចាប់ខ្លួន។ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនរក្សាទុកដើមដីកា ឬចុងដីកា ដែលមានបញ្ជាក់ថា ត្រឹមត្រូវតាមច្បាប់ដើម។ បុគ្គលដែលពាក់ព័ន្ធត្រូវតែបានគេនាំទៅបង្ហាញខ្លួនដល់ចៅក្រមស៊ើបសួរ ឬអ្នកជំនួសចៅក្រមស៊ើបសួរក្នុងរយៈពេលយ៉ាងខ្លីបំផុត ប្រសិនបើស្ថិតក្នុងដំណាក់កាលស៊ើបសួរនៅឡើយ។ ប្រសិនបើការនាំខ្លួនទៅបង្ហាញនេះ តម្រូវឱ្យមានការផ្ទេរបុគ្គលពាក់ព័ន្ធទៅពន្ធនាគារ ឬទៅមណ្ឌលឃុំខ្លួនមួយផ្សេងទៀត ការផ្ទេរនេះត្រូវចាត់ចែងដោយអយ្យការ។ ប្រសិនបើបុគ្គលពាក់ព័ន្ធមិនត្រូវបានគេនាំខ្លួនទៅបង្ហាញដល់ចៅក្រមស៊ើបសួរ ឬអ្នកជំនួសចៅក្រមស៊ើបសួរ នៅថ្ងៃបន្ទាប់ពីការចាប់ខ្លួន បុគ្គលនេះត្រូវតែបានព្រះរាជអាជ្ញានាំទីកន្លែងឃុំខ្លួនស្តាប់ចម្លើយ។ ព្រះរាជអាជ្ញាត្រូវធ្វើកំណត់ហេតុស្តីពីការស្តាប់ចម្លើយ រួចហើយត្រូវបញ្ជូនកំណត់ហេតុស្តីពីការស្តាប់ចម្លើយទៅចៅក្រមស៊ើបសួរ។[52] កាលណាបុគ្គលណាម្នាក់ដែលត្រូវបានចាប់ខ្លួន ដោយអនុវត្តតាមដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវបានឃុំខ្លួន នោះថិរវេលានៃការឃុំខ្លួន ត្រូវរាប់បញ្ចូលទៅក្នុងថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ប្រសិនបើមាន។[53]

**កថាខណ្ឌទី៤៖ ការឃុំខ្លួនបណ្តោះអាសន្ន**

ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការមួយដែលផ្តល់អំណាចធំបំផុតទៅឱ្យចៅក្រមស៊ើបសួរ។ ប៉ុន្តែវិធានការនេះ វាប៉ះពាល់ដល់សេរីភាពរបស់ជនត្រូវចោទ ព្រោះជាគោលការណ៍ជនត្រូវចោទត្រូវតែមានសេរីភាព ហើយការឃុំខ្លួនបុគ្គលណាម្នាក់ ត្រូវមានសេចក្តីសម្រេចស្ថាពរពីតុលាការ។ តែដោយយោងទៅលើស្ថានភាពចាំបាច់ដើម្បីឱ្យការស៊ើបសួរប្រព្រឹត្តទៅបានល្អចៅក្រមស៊ើបសួរគាត់អាចចេញដីកាឃុំខ្លួនបណ្តោះអាសន្នបាន។[54]

[51] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា១៩៩។

[52] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២០១។

[53] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២០២។

[54] អាន ស៊ូរីដា, ដំណើរការរឿងក្តីព្រហ្មទណ្ឌនៅកម្ពុជាបច្ចុប្បន្ន, ភ្នំពេញ៖ ឈីវទីម៉ិច គ្រុប, ទំព័រ៥៧។

ការឃុំខ្លួនបណ្តោះអាសន្នជាគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាព។ ក្នុងករណីពិសេស ជនត្រូវចោទអាចត្រូវឃុំខ្លួនបណ្តោះអាសន្ន នៅក្នុងលក្ខខណ្ឌដែលបានចែងក្នុងករណីនៃការឃុំខ្លួនបណ្តោះអាសន្នអាចអនុវត្តបានតែក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលច្បាប់កំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១ (មួយ) ឆ្នាំ។[55]

**ក. មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន**

មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្នអាចត្រូវបានបង្គាប់ កាលណាការឃុំខ្លួនបណ្តោះអាសន្ននេះជាការចាំបាច់ ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី រារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត។ ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ ធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី ការពារសន្តិសុខឱ្យជនត្រូវចោទ និងធានារក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឱ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស។[56]

ប្រសិនបើនៅពេលផ្តើមការស៊ើបសួរចៅក្រមស៊ើបសួរមិនបានឃុំខ្លួនបណ្តោះអាសន្នទេ ដោយគ្រាន់តែដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យតាមផ្លូវតុលាការប៉ុណ្ណោះ។ ប៉ុន្តែនៅពេលជនត្រូវចោទ បានរំលោភបំពានលើកាតព្វកិច្ច ចៅក្រមស៊ើបសួរអាចឃុំខ្លួនបណ្តោះអាសន្នបាន ដោយមិនចាំបាច់យោងតាមមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន) ទេ និងមិនគិតអំពីបទល្មើសអ្វីទាំងអស់។ កាលណាចៅក្រមស៊ើបសួរ ចេញដីកាឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមស៊ើបសួរនេះ ត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។ ព្រះរាជអាជ្ញាអាចប្តឹងឧទ្ធរណ៍បានក្នុងរយៈពេល ៤៨ (សែសិបប្រាំបី) ម៉ោង និងដោយពិរុទ្ធជនក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ គិតពីថ្ងៃដែលចៅក្រមស៊ើបសួរសម្រេចការឃុំខ្លួន។ កាលណាចៅក្រមស៊ើបសួរទទួលបណ្តឹង តាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា សុំឱ្យឃុំខ្លួនបណ្តោះអាសន្ន ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមត្រូវចេញដីកាសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ដោយមិនចាំបាច់មានសំអាងហេតុទេ តែត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាអំពីសេចក្តីសម្រេចនេះ។ ប្រសិនបើមិនសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ នេះទេ ព្រះរាជអាជ្ញាអាចប្តឹងទៅសភាស៊ើបសួរដែលនឹងសម្រេចជំនួស។[57]

**ខ. ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន**

ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងបទឧក្រិដ្ឋ ចំពោះនីតិជនដែលត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៦ (ប្រាំមួយ) ខែបានទេ។ ប៉ុន្តែនៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរ

[55] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២០៣, ២០៤។

[56] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២០៥។

[57] អាន សុវីដា, ដំណើរការរឿងក្តីព្រហ្មទណ្ឌនៅកម្ពុជាបច្ចុប្បន្ន, ភ្នំពេញ៖ ឈីវ៉ទីម៉ិច គ្រុប, ទំព័រ៥៨,៥៩។

អាចពន្យារពេលការឃុំខ្លួនបណ្ដោះអាសន្នម្ដងបាន ៦ (ប្រាំមួយ) ខែ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។ ចៅក្រមស៊ើបសួរអាចសម្រេចពន្យារការឃុំខ្លួនបណ្ដោះអាសន្នបានតែ ២ (ពីរ) ដងគត់។[58] ដោយឡែក ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទមជ្ឈិម ចំពោះនីតិជនដែលត្រូវចោទប្រកាន់ពីបទមជ្ឈិម ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ (បួន) ខែ បានទេ។ ប៉ុន្តែ នៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនបណ្ដោះអាសន្នបានតែម្ដងគត់មិនឱ្យលើសពី ២ (ពីរ) ខែ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។ ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន មិនត្រូវលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ។[59] **ឧទាហរណ៍៖** បទល្មើសមួយ ត្រូវបានច្បាប់កំណត់ផ្ដន្ទាទោសពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ។ ដូច្នេះ ការឃុំខ្លួនបណ្ដោះអាសន្ន មិនត្រូវឱ្យលើសពី ៦ (ប្រាំមួយ) ខែ ទេ។[60]

ដោយឡែក ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋទាក់ទងនឹងអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ដែលត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ ថិរវេលាឃុំខ្លួនបណ្ដោះអាសន្ន មានដូចតទៅ៖ ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ (បួន) ខែ បានទេ កាលណាអនីតិជននោះមានអាយុតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ។ ចំពោះអនីតិជនដែលមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៦ (ប្រាំមួយ) ខែបានទេ។[61] ចំពោះថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទមជ្ឈិមទាក់ទងនឹងអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ដែលត្រូវចោទប្រកាន់ពីបទមជ្ឈិម ថិរវេលាឃុំខ្លួនបណ្ដោះអាសន្នមានដូចតទៅ៖ កាលណាអនីតិជនដែលមានអាយុតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ២ (ពីរ) ខែ បានទេ។ កាលណាអនីតិជនដែលមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ (បួន) ខែ បានទេ។ ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នខាងលើនេះ មិនត្រូវលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សម្រាប់អនីតិជននោះឡើយ។[62]

យោងតាមសេចក្ដីសម្រេចទាក់ទងនឹងអនីតិជនមានអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំ មិនអាចត្រូវឃុំខ្លួនបណ្ដោះអាសន្នទេ។ ចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជននេះឱ្យឪពុកម្ដាយ អ្នកអាណាព្យាបាល ឬ

---

[58] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២០៨។

[59] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២០៩។

[60] អាន សូវីដា, ដំណើរការរឿងក្ដីព្រហ្មទណ្ឌនៅកម្ពុជាបច្ចុប្បន្ន, ភ្នំពេញ៖ ឈីវទីម៉ិច គ្រុប, ទំព័រ៦០។

[61] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២១៣។

[62] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២១៤។

ក្នុងករណីគ្មានអ្នកអាណាព្យាបាល ត្រូវប្រគល់ទៅមជ្ឈមណ្ឌលអប់រំថែរក្សាបណ្ដោះអាសន្ន និងរង់ចាំសេចក្ដីសម្រេចរបស់តុលាការ។[63]

កាលណាចៅក្រមស៊ើបសួរសម្រេច ពន្យារពេលឃុំខ្លួនបណ្ដោះអាសន្ន ចៅក្រមស៊ើបសួរត្រូវឱ្យដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សម្គាល់របស់ជននេះ។ កាលណាជនត្រូវចោទមានមេធាវីអម នោះមេធាវីត្រូវបង្ហាញមធ្យោបាយការពារខ្លួនកូនក្ដីរបស់ខ្លួន។ ចៅក្រមស៊ើបសួរពន្យារការឃុំខ្លួនបណ្ដោះអាសន្ន តាមដីកាដែលមានសំអាងហេតុត្រូវយោងទៅតាមបទប្បញ្ញត្តិនៃមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន)។[64]

### គ. ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ

ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ អាចធ្វើឡើងដោយចៅក្រមស៊ើបសួរ តាមបណ្ដឹងរបស់ព្រះរាជអាជ្ញា និងតាមបណ្ដឹងរបស់ជនត្រូវចោទ។ កាលណាចៅក្រមស៊ើបសួរយល់ឃើញថា ការឃុំខ្លួនបណ្ដោះអាសន្នលែងចាំបាច់ មានន័យថាបទប្បញ្ញត្តិនៃមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន) លែងចាំបាច់ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំវិញបានគ្រប់ពេលវេលា ដោយចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញា ដើម្បីសុំយោបល់ហើយបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ។ ព្រះរាជអាជ្ញាត្រូវផ្ដល់យោបល់របស់ខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុត។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។[65]

ក្នុងករណីបន្ទាន់ចៅក្រមស៊ើបសួរ អាចបង្គាប់ឱ្យដោះលែងជនត្រូវចោទភ្លាម ដោយមិនរង់ចាំយោបល់របស់ព្រះរាជអាជ្ញា ក្នុងករណីដូចជាជនត្រូវចោទមានជំងឺធ្ងន់ធ្ងរដែលត្រូវព្យាបាលនៅមន្ទីរពេទ្យបន្ទាន់។ ប៉ុន្តែចៅក្រមស៊ើបសួរត្រូវចុះអំពីមូលហេតុនៃការបន្ទាន់នេះនៅក្នុងដីកាសម្រេចរបស់ខ្លួន។

### ឃ. តាមបណ្ដឹងរបស់ព្រះរាជអាជ្ញា និងជនត្រូវចោទ

ព្រះរាជអាជ្ញាអាចសុំឱ្យដោះលែងជនត្រូវចោទបានគ្រប់ពេលវេលា។ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្ដឹងសុំតាមរយៈពាក្យសុំទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។ ដីកាដែលសម្រេចមិនព្រមដោះលែងត្រូវមានសំអាងហេតុ។[66]

---

[63] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២១២។

[64] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២១១។

[65] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២១៥។

[66] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២១៦។

ដោយឡែក តាមបណ្ដឹងរបស់ជនត្រូវចោទ អាចដាក់ពាក្យសុំទៅចៅក្រមស៊ើបសួរ ឱ្យដោះលែងនៅក្រៅឃុំបានគ្រប់ពេលវេលា។ ចៅក្រមស៊ើបសួរត្រូវបញ្ជូនពាក្យនោះភ្លាមទៅព្រះរាជអាជ្ញា ដើម្បីផ្ដល់យោបល់ និងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ។ ព្រះរាជអាជ្ញាត្រូវផ្ដល់យោបល់ក្នុងរយៈពេលខ្លីបំផុត។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីពេលបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ជនត្រូវចោទអាចដាក់ពាក្យសុំនៅក្រៅឃុំសាជាថ្មីម្ដងទៀត ទៅចៅក្រមស៊ើបសួរ ឬទៅសភាស៊ើបសួរក្នុងរយៈពេល ១ (មួយ) ខែ បន្ទាប់ពីមានសេចក្ដីសម្រេចបដិសេធពាក្យសុំលើកមុន។ ចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរត្រូវសម្រេចលើពាក្យនេះក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំ។ ដីកាដែលមិនព្រមដោះលែងឱ្យនៅក្រៅឃុំត្រូវតែមានសំអាងហេតុ។ ប្រសិនបើ ចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ជនត្រូវចោទអាចធ្វើពាក្យប្ដឹងផ្ទាល់ទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។[67]

ប្រសិនបើចៅក្រមស៊ើបសួរយល់ព្រម ចៅក្រមស៊ើបសួរអាចដោះលែង ឬដាក់ជននោះឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបាន។ ជាគោលការណ៍ សេចក្ដីសម្រេចឱ្យនៅក្រៅឃុំមិនអាចយកទៅអនុវត្តបានភ្លាមទេ គឺត្រូវទុកឱ្យផុតរយៈពេលប្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាសិន។ លើកលែងតែព្រះរាជអាជ្ញា យល់ព្រមជាលាយលក្ខណ៍អក្សរ និងករណីបន្ទាន់ប៉ុណ្ណោះទើបអាចដោះលែងភ្លាមបាន។ ក្នុងករណីព្រះរាជអាជ្ញាប្ដឹងឧទ្ធរណ៍ ជនត្រូវចោទត្រូវរក្សាទុកនៅក្នុងឃុំ ដើម្បីរង់ចាំសេចក្ដីសម្រេចរបស់សភាស៊ើបសួរ។ ជាគោលការណ៍ច្បាប់មិនបានចែងអំពីការធានាឱ្យនៅក្រៅឃុំទេ។ ប៉ុន្តែមានមូលហេតុ ដែលចែងក្នុងមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន)។ **ឧទាហរណ៍៖** ដើម្បីធានារក្សាជនត្រូវចោទជូនតុលាការចាត់ការតាមនីតិវិធីច្បាប់។ ដូច្នេះ ប្រសិនបើជននោះ មានមូលដ្ឋានធានាច្បាស់លាស់ថា មិនរត់គេចខ្លួនទេ ចៅក្រមស៊ើបសួរអាចឱ្យនៅក្រៅឃុំបាន។ មូលដ្ឋានធានានេះ ចៅក្រមស៊ើបសួរជាអ្នកសម្រេច។[68]

### ខ. ការជូនដំណឹងអំពីការដោះលែងឱ្យនៅក្រៅឃុំ

ដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំត្រូវតែជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។ ចំណុចនេះ បទប្បញ្ញត្តិនៃមាត្រា ២៧៦ (ការដោះលែងជនត្រូវចោទដែលជាប់ឃុំឱ្យមានសេរីភាព) ត្រូវយកមកអនុវត្ត។ ដីកាមិនព្រមដោះលែងឱ្យនៅក្រៅឃុំត្រូវតែជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។ កាលណាចៅក្រមស៊ើបសួរសម្រេចឱ្យដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ ចៅក្រមស៊ើបសួរអាចដាក់ជនត្រូវចោទឱ្យនៅក្រោមការពិនិត្យតាមផ្លូវតុលាការ ក្នុងលក្ខខណ្ឌដែលមានចែងក្នុង

[67] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២១៧។
[68] អាន សូវីដា, ដំណើរការរឿងក្ដីព្រហ្មទណ្ឌនៅកម្ពុជាបច្ចុប្បន្ន, ភ្នំពេញ៖ ឈីវទីម៉ិច គ្រុប, ទំព័រ៦៣,៦៤។

មាត្រា ២២៣ (កាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ) ដល់មាត្រា ២៣០ (ការគេចវេះរបស់ជនត្រូវចោទពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ)។[69]

### កថាខណ្ឌទី៥៖ ដីកាបង្គាប់ឱ្យឃុំខ្លួន

ដីកាបង្គាប់ឱ្យឃុំខ្លួន គឺជាបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួល និងឱ្យឃុំខ្លួនជនត្រូវចោទ។ ចៅក្រមស៊ើបសួរអាចនឹងចេញដីកាបង្គាប់ឱ្យឃុំខ្លួនបាន លុះត្រាតែជនត្រូវចោទជាកម្មវត្ថុនៃដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន។[70]

ដីកាបង្គាប់ឱ្យឃុំខ្លួនមានចុះអត្តសញ្ញាណរបស់ជនត្រូវចោទ ឈ្មោះបទល្មើសដែលចោទប្រកាន់ អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស។ ចៅក្រមស៊ើបសួរដែលចេញដីកា ត្រូវចុះឈ្មោះ និងឋានៈរបស់ខ្លួនមានចុះកាលបរិច្ឆេទ ចុះហត្ថលេខា និងមានបោះត្រា។

ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវតែទទួល និងឃុំខ្លួនបុគ្គលដែលមានដីកាបង្គាប់ឱ្យឃុំខ្លួនរហូតទាល់តែបានទទួលការឱ្យដំណឹងអំពីការដោះលែងឱ្យមានសេរីភាពវិញ។ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនរក្សាទុកដើមដីកាបង្គាប់ឱ្យឃុំខ្លួន ឬចុងដីកា ដែលបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម។[71]

### កថាខណ្ឌទី៦៖ ដីកាសម្រេចឱ្យដាក់ស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ការត្រួតពិនិត្យតាមផ្លូវតុលាការ គឺជាវិធានការដែលកាត់បន្ថយសេរីភាពមួយចំនួនប៉ុណ្ណោះ ស្រាលជាងការឃុំខ្លួនបណ្ដោះអាសន្ន ដោយឱ្យជនត្រូវចោទនៅក្រៅឃុំ។ ប៉ុន្តែត្រូវគោរពកាតព្វកិច្ចមួយ ឬច្រើននៃមាត្រា ២២៣ (កាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ) ដោយមិនកំណត់ពេលវេលាទេ គឺអាស្រ័យទៅលើចៅក្រមស៊ើបសួរជាអ្នកកែប្រែ ឬលុបចោលបានគ្រប់ពេលវេលា។

### ក. លក្ខខណ្ឌគ្រឹះនៃការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ

ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យទៅលើជនណាម្នាក់ គឺជាអំណាចឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបសួរ (ការចោទជនណាម្នាក់) ថាត្រូវសម្រេចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ ឬយ៉ាងណា។ តាំងពីពេលចាប់ផ្ដើមការស៊ើបសួរមក ចៅក្រមស៊ើបសួរមានអំណាចគ្រប់ពេលវេលាក្នុងការសម្រេចដាក់ជនណាម្នាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ ចំពោះអំពើណាមួយដែលប្ដឹងមក ដោយផ្អែកលើអំណាចវាយតម្លៃលើតម្រុយភស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់ថា ជននោះបានប្រព្រឹត្តបទល្មើសដែលប្ដឹងមកចំពោះមុខខ្លួន។ តម្រុយច្បាស់លាស់ និងស៊ីសង្វាក់

---

[69] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២១៨។

[70] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២២០។

[71] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២២២។

(អំពីពិរុទ្ធភាព) ដែលផ្សាភ្ជាប់រវាងបុគ្គលណាម្នាក់ ទៅនឹងអង្គហេតុខ្លះ ឬទាំងអស់ គឺជាអំណាចវាយតម្លៃដោយសេរីរបស់ចៅក្រម។ តម្រុយច្បាស់លាស់ និងស៊ីសង្វាក់ថាជនណាម្នាក់បានចូលរួមប្រព្រឹត្តបទល្មើសក្នុងនាមជាចារី សហចារី អ្នកសមគំនិត គឺជាលក្ខខណ្ឌគ្រឹះ ហើយប្រសិនបើគ្មានតម្រុយបែបនេះទេ ចៅក្រមមិនអាចសម្រេចដាក់ជននោះឱ្យស្ថិតនៅក្រោមការពិនិត្យបាននោះទេ។ ជាលទ្ធផល ក្នុងករណីការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ ដោយអវត្តមាននូវតម្រុយច្បាស់លាស់ ឬស៊ីសង្វាក់គ្នាយ៉ាងខ្លាំងថា បុគ្គលម្នាក់បានចូលរួមក្នុងឋានៈជាចារី ឬអ្នកសមគំនិតដើម្បីប្រព្រឹត្តបទល្មើស ដែលបានប្ដឹងមកចំពោះមុខចៅក្រមស៊ើបសួរ សភាស៊ើបសួរត្រូវតែប្រកាសមោឃភាពចំពោះការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យនោះ។

ដូច្នេះ ចៅក្រមស៊ើបសួរ គ្មានកាតព្វកិច្ចត្រូវតែដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការពិនិត្យគ្រប់អង្គហេតុទាំងអស់ដែលព្រះរាជអាជ្ញាប្ដឹងមកនោះទេ។ ការស៊ើបអង្កេតលើអង្គហេតុខុសគ្នាអំពីការសម្រេចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ។ បុគ្គលណាម្នាក់នឹងអាចត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យលើអង្គហេតុ ដែលប្ដឹងមកចៅក្រមស៊ើបសួរ ហើយចៅក្រមស៊ើបសួរមានកាតព្វកិច្ចស៊ើបសួរបាន កាលណាមានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់អំពីពិរុទ្ធភាពថា បុគ្គលនោះជាប់ពាក់ព័ន្ធនឹងអង្គហេតុល្មើសនោះ។

**ឧទាហរណ៍៖** ទាក់ទងទៅនឹងការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ៖ **ក** បានលក់កាំភ្លើងឱ្យ **ខ** ហើយក្រោយមក **ខ** បានយកកាំភ្លើងនោះទៅបាញ់សម្លាប់ **គ** តែ **ក** មិនបានចូលរួមប្រព្រឹត្តបទល្មើសជាមួយ **ខ** ទេ។ អំពើទាំងពីរនេះ ត្រូវបានចោទប្រកាន់ដោយអយ្យការមកចៅក្រមស៊ើបសួរ។ ថ្វីដ្បិតតែចៅក្រមស៊ើបសួរត្រូវតែស៊ើបសួរលើអង្គហេតុជួញដូរអាវុធ និងអង្គហេតុបាញ់សម្លាប់ក៏ពិតមែន ប៉ុន្តែគាត់មានអំណាចសម្រេចថាដាក់ **ក** ឱ្យស្ថិតនៅក្រោមការពិនិត្យទៅលើបទជួញដូរអាវុធខុសច្បាប់ តែចៅក្រមស៊ើបសួរមិនអាចដាក់ **ក** ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទឃាតកម្មនោះទេ ដោយសារតែគ្មានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់ដែលថា **ក** បានចូលរួមប្រព្រឹត្តបទល្មើសឃាតកម្ម។[72]

### ខ. មូលហេតុនៃការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ

ចៅក្រមស៊ើបសួរអាចប្រើវិធានការនេះ លុះត្រាតែបទល្មើសដែលត្រូវចោទប្រកាន់ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ។ ដោយឡែក ការត្រួតពិនិត្យតាមផ្លូវតុលាការគឺមានគោលដៅសំខាន់ៗ ៤ គឺ៖

- ដើម្បីធានាឱ្យជនត្រូវចោទមកបង្ហាញខ្លួននៅចំពោះមុខតុលាការ
- បន្ថយសេរីភាពមួយចំនួន កុំឱ្យកើតមានបទល្មើសបន្តទៀត
- ដាក់កំហិតនូវការព្យាបាលផ្នែកសង្គម ឬផ្នែកវិជ្ជសាស្ត្រ

[72] ចក សម្បត្តិ, "ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ," (សមាគមសាលាត្រាជូ, វិច្ឆិកា ២០១៧), ទំព័រ៧-៨។

- ដាក់ប្រាក់ធានាដើម្បីទុកសងការខូចខាតដល់ជនរងគ្រោះ។

កាលណាចៅក្រមស៊ើបសួរ ទទួលបណ្តឹងសុំពីព្រះរាជអាជ្ញាឱ្យដាក់ស្ថិតនៅក្រោមការពិនិត្យតាមផ្លូវតុលាការ បើចៅក្រមមិនសម្រេចតាមការសុំរបស់ព្រះរាជអាជ្ញាទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ហើយត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា។ ប្រសិនបើមិនសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាអាចធ្វើពាក្យប្តឹងទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។

ក្នុងនោះមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងអំពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ មានអានុភាពបង្គាប់ជនត្រូវចោទដែលនៅក្រៅឃុំឱ្យគោរពកាតព្វកិច្ចមួយ ឬច្រើនដូចតទៅ៖

- មិនត្រូវចេញក្រៅព្រំប្រទល់ដែនដីកំណត់ដោយចៅក្រមស៊ើបសួរ
- មិនត្រូវផ្លាស់ប្តូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ
- មិនត្រូវទៅកាន់ទីកន្លែងខ្លះ ដែលកំណត់ដោយចៅក្រមស៊ើបសួរ
- ត្រូវចូលបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថដែលចាត់តាំងដោយចៅក្រមស៊ើបសួរ
- ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ
- ប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីគ្រប់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ
- មិនត្រូវបើកបររថយន្ត
- មិនត្រូវទទួល ឬជួបបុគ្គលមួយចំនួន ដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ
- ដាក់ប្រាក់ធានាដែលចំនួនប្រាក់ធានា និងចិរវេលាបង់ប្រាក់នេះ ត្រូវបានកំណត់ដោយចៅក្រមស៊ើបសួរដោយផ្អែកទៅលើធនធានរបស់ជនត្រូវចោទ
- មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ។ ត្រូវប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីនូវអាវុធដែលជនត្រូវចោទកាន់កាប់
- ត្រូវប្រគល់ខ្លួនឱ្យពេទ្យពិនិត្យព្យាបាល និងជាយថាហេតុដាក់ឱ្យស្ថិតនៅក្រោមរបបព្យាបាលរោគក្នុងមន្ទីរពេទ្យ
- មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ។

ដើម្បីអនុវត្តចំណុចទាំង ១២ ខាងលើ ចៅក្រមស៊ើបសួរមិនអាចហាមឃាត់ការអនុវត្តនូវអាណត្តិបោះឆ្នោត ឬសកម្មភាពខាងសហជីពបានទេ។

**កថាខណ្ឌទី៧៖ ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការ**

**ក. ដោយចៅក្រមស៊ើបសួរ**

ចៅក្រមស៊ើបសួរ អាចកែប្រែខ្លឹមសារនៃកាតព្វកិច្ច អាចលុបចោល ឬបញ្ចូលកាតព្វកិច្ចថ្មីបានគ្រប់ពេលវេលា។ ចៅក្រមស៊ើបសួរក៏អាចបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការបាន តាមរយៈដីកាដែលត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។[73]

**ខ. ដោយព្រះរាជអាជ្ញា**

ព្រះរាជអាជ្ញាអាចសុំលើកលែង ឬកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា។ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ហើយដីកានេះត្រូវជូនដំណឹងក្នុងរយៈពេលខ្លីបំផុតដល់ព្រះរាជអាជ្ញា។ ប្រសិនបើចៅក្រមស៊ើបសួរ មិនបានសម្រេចក្នុងរយៈពេលនេះទេ ព្រះរាជអាជ្ញាអាចធ្វើពាក្យសុំទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។ ដីកាដែលសម្រេចមិនព្រមធ្វើតាមបណ្តឹងសុំរបស់ព្រះរាជអាជ្ញាត្រូវតែមានសំអាងហេតុ។[74]

**គ. ដោយជនត្រូវចោទ**

ជនត្រូវចោទអាចធ្វើពាក្យសុំឱ្យលើកលែង ឬកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា។ ចៅក្រមស៊ើបសួរបញ្ជូនពាក្យសុំនេះភ្លាមទៅព្រះរាជអាជ្ញា ដើម្បីសុំយោបល់ និងជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ គិតពីថ្ងៃបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ដីកាសម្រេចនេះត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។ កាលណាមានពាក្យសុំឱ្យលើកលែង ឬឱ្យកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានធ្វើជាថ្មី មុនពេលចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរសម្រេចលើពាក្យសុំពីមុននោះ រយៈពេល ៥ (ប្រាំ) ថ្ងៃនេះ ត្រូវចាប់ផ្តើមគិតពីពេលចេញសេចក្តីសម្រេចលើពាក្យសុំពីមុន។ ដីកាដែលសម្រេចមិនព្រមធ្វើតាមពាក្យសុំ ត្រូវតែមានសំអាងហេតុ។ ប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃនេះទេ ជនត្រូវចោទអាចធ្វើពាក្យប្តឹងទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។[75]

**កថាខណ្ឌទី៨៖ ការគេចវេះពីកាតព្វកិច្ច**

ប្រសិនបើជនត្រូវចោទគេចវេះដោយចេតនាពីកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរអាចសម្រេចឱ្យឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នបាន ទោះបីទោសជាប់ពន្ធនាគារដែលត្រូវរងនោះមានថិរវេលា

---

[73] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២២៧។

[74] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២២៨។

[75] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២២៩។

ប៉ុន្មានក៏ដោយ ហើយទោះជាជនត្រូវចោទត្រូវបានឃុំខ្លួនបណ្ដោះអាសន្នអស់រយៈពេលអតិបរមាដែលមានចែង ដោយមាត្រា ២០៨ (ចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋ) ដល់មាត្រា ២១៤ (ចិរវេលានៃការឃុំខ្លួន បណ្ដោះអាសន្ននៅក្នុងបទមជ្ឈិមទាក់ទងនឹងអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ ប្រាំបី) ឆ្នាំ នៃក្រមនេះក៏ដោយ។ កាលណាចៅក្រមស៊ើបសួរសម្រេចថានឹងឃុំខ្លួនបណ្ដោះអាសន្នដោយមូលហេតុ ខាងលើនេះ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សម្គាល់របស់ជនត្រូវចោទ។ ចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជនត្រូវចោទ តាមដីកាដែលមានសំអាងហេតុ ត្រូវជូនដំណឹងភ្លាមដល់ព្រះរាជ អាជ្ញា ដល់ជនត្រូវចោទ និងមេធាវីរបស់ជនត្រូវចោទ (ប្រសិនបើមាន)។ ហើយការឃុំខ្លួនបណ្ដោះអាសន្ននេះ មិនអាចឱ្យលើសពី ៤ (បួន) ខែ ចំពោះនីតិជន និង ២ (ពីរ) ខែ ចំពោះអនីតិជន។[76]

បន្ទាប់ពីសិក្សាអំពីវិធានការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួររួចមក ជាបន្តទៀតយើងនឹងសិក្សាអំពីការ បិទការស៊ើបសួររបស់ចៅក្រមស៊ើបសួរ ដែលយើងនឹងសិក្សាអំពី នីតិវិធីនៃការបិទការស៊ើបសួរ (ផ្នែកទី១) និង ប្រភេទដីកាដំណោះស្រាយ (ផ្នែកទី២)។

[76] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២៣០។

# ជំពូកទី៣
# ការបិទការស៊ើបសួរ

## ផ្នែកទី១៖ នីតិវិធីនៃការបិទការស៊ើបសួរ

នៅពេលដែលចៅក្រមស៊ើបសួរយល់ឃើញថា ការស៊ើបសួរបានបញ្ចប់សព្វគ្រប់ហើយ ចៅក្រមស៊ើបសួរ បិទសំណុំរឿងក្រោមកិច្ចមួយហៅថា ដីកាដំណោះស្រាយ។ ជាទូទៅ ការស៊ើបសួរពុំមានកំណត់រយៈពេលទេ ប៉ុន្តែបើការស៊ើបសួរបានអូសបន្លាយអស់រយៈពេល ១ (មួយ) ឆ្នាំ ព្រះរាជអាជ្ញាអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើការបញ្ចប់កិច្ចស៊ើបសួរបាន ហើយជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីក៏អាចសុំឱ្យចៅក្រមស៊ើបសួរធ្វើការបិទការស៊ើបសួរបានដែរ។[77] ចៅក្រមស៊ើបសួរ ត្រូវសម្រេចក្នុងរយៈពេល ១ (មួយ) ខែ គិតពីថ្ងៃទទួលពាក្យរបស់ដើមចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីដែលប្តឹងសុំ។ ប្រសិនបើមិនសម្រេចក្នុងរយៈពេលនេះទេ ព្រះរាជអាជ្ញា ឬអ្នកសុំអាចប្តឹងទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។[78]

### កថាខណ្ឌទី១៖ ការជូនព័ត៌មានដោយចៅក្រមស៊ើបសួរ

#### ក. ការជូនដំណឹងដល់គូភាគី

នៅពេលបិទបញ្ចប់ការស៊ើបសួរ ចៅក្រមស៊ើបសួរមានកាតព្វកិច្ចជូនដំណឹងទៅកាន់គ្រប់ភាគីដែលពាក់ព័ន្ធពោលគឺ ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី (ប្រសិនបើមាន)។ ដោយឡែកការជូនដំណឹងនេះទៀតសោត គ្មានទម្រង់ណាមួយច្បាស់លាស់នោះទេ។ បន្ទាប់ពីបានជូនដំណឹងក្នុងរយៈពេល ២ (ពីរ) ថ្ងៃ ចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ការបញ្ជូនសំណុំរឿងគឺជាការចាំបាច់សម្រាប់ឱ្យព្រះរាជអាជ្ញាអាចដាក់ពាក្យសុំឱ្យធ្វើកិច្ចស៊ើបសួរ បើគាត់យល់ឃើញថា ការស្រាវជ្រាវផ្សេងទៀតចាំបាច់ដើម្បីបំពេញការស៊ើបសួរដែលធ្វើរួច។ មិនតែប៉ុណ្ណោះ ការបញ្ជូនសំណុំរឿងក៏ជាការចាំបាច់ ដើម្បីអនុញ្ញាតឱ្យព្រះរាជអាជ្ញាផ្តល់យោបល់ទៅលើដំណាក់កាលបន្តនៃសំណុំរឿង តាមរយៈដីកាសន្និដ្ឋានស្ថាពរ។

បន្ទាប់ពីបានបំពេញកិច្ចស៊ើបសួរដែលសុំដោយគូភាគី ចៅក្រមស៊ើបសួរត្រូវជូនដំណឹងសារជាថ្មីទៅកាន់ភាគីថា គាត់យល់ឃើញថាការស៊ើបសួរត្រូវបិទបញ្ចប់។ ការជូនដំណឹងនេះត្រូវមានចិរវេលា ២ (ពីរ) ថ្ងៃ មុនការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ដូចគ្នានេះដែរ បន្ទាប់ពីទទួលសំណុំរឿង ប្រសិនបើព្រះរាជអាជ្ញាសុំឱ្យមានកិច្ចស៊ើបសួរបន្ថែម ហើយការសុំឱ្យមានការស៊ើបសួរបន្ថែមនេះ ត្រូវបានយល់ព្រមដោយចៅក្រមស៊ើបសួរ

[77] សុខ រឿន, មេរៀននីតិវិធីព្រហ្មទណ្ឌ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ទំព័រ៥០,៥១

[78] អាន សូវីដា, ដំណើរការរឿងក្តីព្រហ្មទណ្ឌនៅកម្ពុជាបច្ចុប្បន្ន, ភ្នំពេញ៖ ឈីវទីម៉ិច គ្រុប, ទំព័រ៧៤។

ផងដែរ។ ហេតុនេះ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងពីការបញ្ចប់ការស៊ើបសួរជាថ្មីម្តងទៀត នៅពេលដែលកិច្ចស៊ើបសួរបន្ថែមនោះត្រូវបានធ្វើចប់សព្វគ្រប់ និងបានចុះលេខក្នុងសំណុំរឿង។[79]

### ខ. ការស្នើសុំបំពេញកិច្ចបន្ថែម

ការស្នើសុំបំពេញកិច្ចបន្ថែម គឺជានីតិវិធីមួយដែលអនុញ្ញាតឱ្យព្រះរាជអាជ្ញា សុំឱ្យចៅក្រមស៊ើបសួរបើកការស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ក្នុងការសម្តែងឱ្យឃើញការពិត។ ក្នុងករណីមានការស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែមណាមួយ ចៅក្រមស៊ើបសួរមិនជាប់កាតព្វកិច្ចត្រូវតែស៊ើបសួរតាមការស្នើសុំនោះទេ គឺចៅក្រមស៊ើបសួរអាចបដិសេធស៊ើបសួរ ឬស៊ើបសួរបន្ថែមក៏បាន ប៉ុន្តែត្រូវជូនដំណឹងដល់អ្នកស្នើសុំ។ ប្រសិនបើគ្មានការជូនដំណឹងអំពីការបដិសេធដល់អ្នកស្នើសុំទេ នោះអ្នកស្នើសុំអាចប្តឹងឧទ្ធរណ៍ទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ ប៉ុន្តែការប្តឹងនេះ គឺប្តឹងត្រឹមតែកម្មវត្ថុដែលមានចែងក្នុងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែមតែប៉ុណ្ណោះ។

យើងសង្កេតឃើញថា នៅគ្រប់ពេលវេលានៃការស៊ើបសួរ ព្រះរាជអាជ្ញា អាចស្នើសុំឱ្យចៅក្រមស៊ើបសួរធ្វើកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍។ ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមស៊ើបសួរតាមការស្នើសុំទេ នោះចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធនៅក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ហើយត្រូវមានសំអាងហេតុ និងត្រូវជូនដំណឹងទៅដល់ព្រះរាជអាជ្ញាក្នុងចិរវេលាយ៉ាងឆាប់បំផុត។ ករណីចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃទេ ព្រះរាជាអាជ្ញាអាចប្តឹងដោយផ្ទាល់ទៅសភាស៊ើបសួរតាមរយៈពាក្យសុំ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។[80]

### កថាខណ្ឌទី២៖ ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា

កាលណាចៅក្រមស៊ើបសួរយល់ឃើញថា ការស៊ើបសួរបានបញ្ចប់ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មាននេះដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី (ប្រសិនបើមាន)។ ក្នុងរយៈពេល ២ (ពីរ) ថ្ងៃក្រោយមក ចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ។ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថា ចាំបាច់ត្រូវធ្វើកិច្ចស៊ើបសួរថ្មីទៀតនោះ ព្រះរាជអាជ្ញាត្រូវធ្វើតាមមាត្រា ១៣២ (ការស្នើសុំបំពេញកិច្ចដោយព្រះរាជអាជ្ញា)។ ដោយឡែកក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ប្រសិនបើជនត្រូវចោទត្រូវឃុំខ្លួន និង ១ (មួយ) ខែ ក្នុងករណីដែលជនត្រូវចោទនៅក្រៅឃុំ ព្រះរាជអាជ្ញាត្រូវបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ ដោយមានដីកាសន្និដ្ឋានស្ថាពរភ្ជាប់ជាមួយផង។ ចិរវេលានេះ ត្រូវគិតពីថ្ងៃដែលព្រះរាជអាជ្ញាបានទទួលសំណុំរឿង។

---

[79] សុខ រឿន, មេរៀននីតិវិធីព្រហ្មទណ្ឌ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ទំព័រ៥២។

[80] សុខ រឿន, មេរៀននីតិវិធីព្រហ្មទណ្ឌ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ទំព័រ៥២,៥៣។

ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញដូចចៅក្រមស៊ើបសួរដែរថា ការស៊ើបសួរត្រូវបញ្ចប់នោះ ព្រះរាជអាជ្ញាត្រូវធ្វើដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។ ព្រះរាជអាជ្ញា អាចប្តឹងឱ្យចៅក្រមស៊ើបសួរសម្រេចបញ្ជូនខ្លួនជនត្រូវចោទទៅកាន់តុលាការជំនុំជម្រះ ឬក៏លើកលែងការចោទប្រកាន់។[81]

ការបិទការស៊ើបសួរស្តែងឡើងតាមរយៈដីកាដំណោះស្រាយ។ ដីកាដំណោះស្រាយនេះ ធ្វើឡើងក្នុងពីរដំណាក់កាល ដោយដំណាក់កាលទីមួយ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ (ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី) អំពីឆន្ទៈរបស់ខ្លួនក្នុងការបិទការស៊ើបសួរនៃសំណុំរឿង។ ដោយឡែកដំណាក់កាលទីពីរ ចៅក្រមស៊ើបសួរអាចចេញដីកាបិទសំណុំរឿងបាន។ ក្នុងករណីចៅក្រមស៊ើបសួរពុំទាន់ចេញដីកាបិទសំណុំរឿងទេ បានន័យថា ទោះជាបន្ទាប់ពីបានជូនដំណឹងដល់ភាគីពីឆន្ទៈបិទសំណុំរឿងរួចហើយក៏ដោយ ក៏ចៅក្រមស៊ើបសួរនៅតែអាចទទួលបណ្តឹង និងអាចបន្តការស្រាវជ្រាវរបស់ខ្លួនបានដែរ។

ដើម្បីជាប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី ឬជនត្រូវចោទ នៅពេលផុតថិរវេលា ១ (មួយ) ឆ្នាំ គិតពីថ្ងៃចោទប្រកាន់ ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី អាចសុំឱ្យចៅក្រមស៊ើបសួរបិទការស៊ើបសួរបាន។ ក្នុងរយៈពេល ១ (មួយ) ខែ គិតពីថ្ងៃទទួលពាក្យសុំ ចៅក្រមស៊ើបសួរត្រូវតែសម្រេច។ ប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចក្នុងរយៈពេល ១ (មួយ) ខែទេ ជនត្រូវចោទអាចប្តឹងទៅប្រធានសភាស៊ើបសួរ ដែលធ្វើអធិបញ្ជាដល់ចៅក្រមស៊ើបសួរឱ្យសម្រេច។ ក្នុងករណីពិសេស អំណាចដែលអនុវត្តដោយជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានប្រើប្រាស់ដោយមេធាវី។[82]

ដោយឡែក តាមរយៈដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញាអាចសុំឱ្យបើកការស៊ើបសួរជាថ្មី ដើម្បីស្រាវជ្រាវបន្ថែម សុំឱ្យលើកលែងការចោទប្រកាន់ ឬសម្រេចបញ្ជូនសំណុំរឿងទៅសាលាជំនុំជម្រះ។

## ផ្នែកទី២៖ ប្រភេទដីកាដំណោះស្រាយ

នៅក្នុងដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរសម្រេចអំពីការប្រគល់សងទៅឱ្យម្ចាស់ដើមវិញនូវវត្ថុដែលចាប់យក។ យើងសង្កេតឃើញថា បើចេញដីកាដំណោះស្រាយ នោះត្រូវបញ្ចប់ការឃុំខ្លួនបណ្តោះអាសន្ន ប៉ុន្តែតាមសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរអាចរក្សាជនត្រូវចោទឱ្យនៅជាប់ឃុំបណ្តោះអាសន្នរហូតដល់ពេលចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ តែក្នុងដីកាត្រូវមានបញ្ជាក់អំពីមូលហេតុ។ បន្ថែមពីនេះទៀត ដីកាដំណោះស្រាយក៏អាចបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការបានដែរ ប៉ុន្តែតាមសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរអាចរក្សាទុកជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួត

[81] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២៤៦។

[82] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២៨៦។

ពិនិត្យតាមផ្លូវតុលាការ រហូតដល់ពេលចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ។[83] មិនតែប៉ុណ្ណោះ ដីកាដំណោះស្រាយដែលចូលជាស្ថាពរ មានអានុភាពលុបបំបាត់ចោលពីសំណុំរឿងនូវគ្រប់មោឃភាពទាំងអស់នៃនីតិវិធីមុនប្រសិនបើមាន។ គ្មានមោឃភាពណាមួយនៃនីតិវិធីមុន អាចត្រូវបានលើកឡើងនៅចំពោះមុខតុលាការជំនុំជម្រះបានទៀតឡើយ។[84]

ដីកាដំណោះស្រាយជានិច្ចកាលត្រូវតែមានសំអាងហេតុ។ ចៅក្រមស៊ើបសួរ មិនត្រូវជាប់កាតព្វកិច្ចគោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាទេ។ ដីកាអាចជាដីកាបញ្ជូនទៅតុលាការជំនុំជម្រះចំពោះអំពើមួយចំនួន និងជាដីកាលើកលែងការចោទប្រកាន់ចំពោះអំពើដទៃទៀត។ ក្នុងករណីដែលសំណុំរឿងស៊ើបសួរពាក់ព័ន្ធនឹងអង្គហេតុច្រើន ចៅក្រមស៊ើបសួរអាចចេញដីកាដំណោះស្រាយចំពោះអង្គហេតុដែលការស៊ើបសួរបានចប់សព្វគ្រប់ និងបន្តការស៊ើបសួរចំពោះអង្គហេតុផ្សេងទៀតបាន។ ចៅក្រមស៊ើបសួរក៏អាចចេញដីកាលើកលែងការចោទប្រកាន់ ចំពោះជនត្រូវចោទដែលត្រូវបានស៊ើបសួរឃើញថា មិនមានការពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើស ឬការចូលរួមប្រព្រឹត្តបទល្មើស និងធ្វើការស៊ើបសួររកអត្តសញ្ញាណជនល្មើសបន្តទៀតបាន។ ដីកាដំណោះស្រាយត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី។[85]

ក្រោយពីបានទទួលនូវសេចក្ដីសន្និដ្ឋានស្ថាពរពីអយ្យការហើយ ចៅក្រមស៊ើបសួរត្រូវធ្វើចំណាត់ការលើសំណុំរឿងដោយធ្វើសេចក្ដីសន្និដ្ឋានតាមរយៈដីកាដំណោះស្រាយ។ ដីកាដំណោះស្រាយនេះ អាចជាដីកាលើកលែងការចោទប្រកាន់ ឬដីកាបញ្ជូនទៅជំនុំជម្រះ។

### កថាខណ្ឌទី១៖ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

តាមរយៈដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថាមានបន្ទុកគ្រប់គ្រាន់ ដើម្បីធ្វើការចោទប្រកាន់ជនត្រូវចោទពីបទល្មើសព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿង និងជនត្រូវចោទទៅជំនុំជម្រះ។ នៅក្នុងដីកាបញ្ជូនទៅជំនុំជម្រះ អាចជាអំពើទាំងអស់ ឬមួយផ្នែកនៃសំណុំរឿង មានន័យថាអាចអំពើខ្លះធ្វើការលើកលែងចោទប្រកាន់ ហើយអំពើខ្លះទៀតជាកម្មវត្ថុនៃការចោទប្រកាន់។ នៅពេលដែលចៅក្រមស៊ើបសួរ ចេញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿង និងភស្តុតាងដែលមានទៅប្រធានតុលាការ ដើម្បីកំណត់ពេលសវនាការជំនុំជម្រះ។ ចៅក្រមស៊ើបសួរអាចរក្សាជនត្រូវចោទឱ្យនៅជាប់ឃុំបណ្ដោះអាសន្ន រហូតដល់ចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ (ប្រសិនបើជនត្រូវ

---

[83] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២៤៩។

[84] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២៥៦។

[85] ច្បាប់ស្ដីពីវិសោធនកម្មមាត្រា២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៦១៣/០០៩, ០៩ មិថុនា ២០១៣, មាត្រា ២៤៧។

ចោទនោះនៅជាប់ឃុំខ្លួនបណ្តោះអាសន្ន)។[86] ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថាអំពើនោះជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទទៅតុលាការជំនុំជម្រះ។ ដីកានេះត្រូវរៀបរាប់អំពីអំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់។[87]

**កថាខណ្ឌទី២៖ ដីកាលើកលែងការចោទប្រកាន់**

តាមរយៈដីកាលើកលែងការចោទប្រកាន់ ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថា អង្គហេតុនៃអំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុទេ ឬជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់ ឬគ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ទៅលើជនត្រូវចោទ ឬករណីដែលបណ្តឹងអាជ្ញារលត់ ដែលបញ្ជាក់ថាជនត្រូវចោទមានពិរុទ្ធភាពនោះទេ ចៅក្រមស៊ើបសួរសម្រេចចេញដីកាលើកលែងការចោទប្រកាន់។[88] ការសម្រេចចេញដីកាលើកលែងការចោទប្រកាន់នេះ ត្រូវមានចែងមូលហេតុច្បាស់លាស់ និងត្រូវជូនដំណឹងទៅដល់គ្រប់ភាគីទាំងអស់ ដើម្បីអាចឱ្យភាគីដែលមិនសុខចិត្តនឹងដីកាសម្រេចលើកលែងការចោទប្រកាន់នេះ អាចធ្វើការតវ៉ា ឬដាក់ពាក្យបណ្តឹងឧទ្ធរណ៍បាន។ លើសពីនេះ ចៅក្រមស៊ើបសួរអាចចេញដីកាលើកលែងការចោទប្រកាន់ ក្នុងករណីរលត់បណ្តឹងអាជ្ញា ផុតអាជ្ញាយុកាល ឬមរណភាពនៃចារី។

ក្នុងករណីដែលមានការលើកលែងការចោទប្រកាន់ដោយមូលហេតុអត្តសញ្ញាណរបស់ជនត្រូវចោទមិនត្រូវបានស្គាល់ ឬក្នុងករណីដែលជនត្រូវចោទទទួលមរណភាព ចៅក្រមស៊ើបសួរអាចប្តឹងសុំទៅតុលាការព្រហ្មទណ្ឌតាមដីកាបញ្ជូនឱ្យសម្រេចរឹបអូសឧបករណ៍ សម្ភារៈ មូលនិធិ ផលទុន ឬទ្រព្យសម្បត្តិ ប្រសិនបើមានការសង្ស័យដោយសមហេតុផលថាពាក់ព័ន្ធនឹងបទល្មើស។ ករណីនេះ តុលាការព្រហ្មទណ្ឌត្រូវសម្រេចអំពីការរឹបអូសដោយសាលក្រមក្នុងសវនាការជាសាធារណៈ ដោយមានការចូលរួមពីតំណាងអយ្យការ និងបុគ្គលពាក់ព័ន្ធ (បើមាន)។ សាលក្រមដែលសម្រេចអំពីការរឹបអូស ត្រូវបិទផ្សាយនៅទីកន្លែងដែលតុលាការបានចេញសាលក្រម និងផ្សាយជាសាធារណៈតាមសារព័ត៌មាន ឬមធ្យោបាយទូរគមនាគមន៍ សោតទស្សន៍។ បុគ្គលដែលមានប្រយោជន៍ពាក់ព័ន្ធ ឬដែលអះអាងថាខ្លួនជាម្ចាស់នៃវត្ថុដែលជាកម្មវត្ថុនៃការរឹបអូស មានសិទ្ធិប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនោះបានក្នុងរយៈពេល ១ (មួយ) ខែ គិតពីថ្ងៃប្រកាសសាលក្រម ប្រសិនបើបុគ្គលនេះបានចូលរួមនៅក្នុងនីតិវិធីនៃការជំនុំជម្រះរបស់តុលាការ និងក្នុងរយៈពេល ២ (ពីរ) ខែ គិតពីថ្ងៃប្រកាសផ្សាយជាសាធារណៈតាមសារព័ត៌មាន ឬមធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ ប្រសិនបើបុគ្គលនេះមិនបានចូលរួមនៅ

---

[86] សុខ រឿន, មេរៀននីតិវិធីព្រហ្មទណ្ឌ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ទំព័រ៥៦។

[87] ច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៦១៣/០០៩, ០៩ មិថុនា ២០១៣, មាត្រា ២៤៧។

[88] ច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៦១៣/០០៩, ០៩ មិថុនា ២០១៣, មាត្រា ២៤៧។

ក្នុងនីតិវិធីតុលាការ។ បែបបទ និងនីតិវិធីនៃការប្តឹងឧទ្ធរណ៍ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។[89]

ដីកាលើកលែងការចោទប្រកាន់មិនរលត់បណ្តឹងអាជ្ញាទេ ប្រសិនបើការលើកលែងការចោទប្រកាន់មកពីហេតុផលអវត្តមាននៃបន្ទុកគ្រប់គ្រាន់ប្រឆាំងនឹងជនត្រូវចោទ ឬមកពីការពុំស្គាល់ចារីឡើយ ដូច្នេះ ប្រសិនបើមានបន្ទុកថ្មីលេចឡើង អនុញ្ញាតឱ្យបើកការស៊ើបសួរទៅលើអង្គហេតុនោះជាថ្មីម្តងទៀតបាន។[90]

**កថាខណ្ឌទី៣៖ ការបើកការស៊ើបសួរលើបន្ទុកថ្មី**

ការបើកការស៊ើបសួរលើបន្ទុកថ្មីនេះ គឺនៅក្រោយពេលដែលដីកាលើកលែងការចោទប្រកាន់របស់ចៅក្រមស៊ើបសួរ ឬសាលដីកាលើកលែងការចោទប្រកាន់របស់សភាស៊ើបសួរបានចូលជាស្ថាពរ ប្រសិនបើមានលេចឡើងបន្ទុកថ្មី ការបើកការស៊ើបសួរអាចបើកឡើងវិញ តាមការស្នើសុំ ឬការផ្តើមគំនិតរបស់ព្រះរាជអាជ្ញា។[91] ចំណែកសំណុំរឿងដែលអាចយកមកបើកការស៊ើបសួរលើបន្ទុកថ្មីបាននោះ លុះត្រាតែដីកាលើកលែងការចោទប្រកាន់របស់ចៅក្រមស៊ើបសួរមិនបានធ្វើឱ្យរលត់នៃបណ្តឹងអាជ្ញា បានន័យថាប្រសិនបើដីកាលើកលែងការចោទប្រកាន់របស់ចៅក្រមស៊ើបសួរធ្វើឱ្យរលត់នៃបណ្តឹងអាជ្ញាដោយមូលហេតុដូចជា មរណភាពនៃចារី ផុតអាជ្ញាយុកាល ការលើកលែងទោសជាទូទៅ និរាករណ៍នៃច្បាប់ ឬអាជ្ញាអស់ជំនុំ ហេតុនេះព្រះរាជអាជ្ញាមិនអាចស្នើសុំ ឬផ្តើមគំនិតឱ្យបើកការស៊ើបសួរលើបន្ទុកថ្មីបាននោះទេ។

[89] ច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៦១៣/០០៩, ០៩ មិថុនា ២០១៣, មាត្រា ២៤៧។

[90] សុខ ឿន, មេរៀននីតិវិធីព្រហ្មទណ្ឌ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ទំព័រ៥៥។

[91] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២៥១។

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីយើងខ្ញុំទាំងពីរ បានធ្វើការសិក្សាស្រាវជ្រាវអំពីប្រធានបទស្តីពី **“តួនាទី និងភារកិច្ចរបស់ចៅក្រមស៊ើបសួរ”** រួចមក យើងខ្ញុំអាចទាញជាសេចក្តីសន្និដ្ឋានបានថា មន្ទីរស៊ើបសួរនៅតាមសាលាដំបូងរាជធានី-ខេត្ត មានចៅក្រមស៊ើបសួរចូលរួម និងដើរតួនាទីយ៉ាងសំខាន់ក្នុងការស៊ើបសួរ ព្រមទាំងដឹកនាំការស៊ើបសួរក្នុងគោលបំណងស្វែងរកនូវភស្តុតាងនានា ដើម្បីបង្ហាញឱ្យឃើញការពិតនៃសំណុំរឿងព្រហ្មទណ្ឌ។ អំណាចរបស់ចៅក្រមស៊ើបសួរនៅក្នុងដំណាក់កាលស៊ើបសួរ គឺមានកំណត់នៅក្នុងច្បាប់ ពោលគឺមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧។ ការបើកការស៊ើបសួររបស់ចៅក្រមស៊ើបសួរ អាចធ្វើឡើងដោយកត្តាពីរគឺ ទីមួយតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់តំណាងអយ្យការ និងទីពីរតាមរយៈបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ នៅពេលដែលចៅក្រមស៊ើបសួរទទួលបានសំណុំរឿងដោយមានភ្ជាប់មកជាមួយនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នោះចៅក្រមស៊ើបសួរអាចធ្វើការចាប់ផ្តើមបំពេញកាតព្វកិច្ចរបស់ខ្លួនបាន។ ចៅក្រមស៊ើបសួរអាចធ្វើការស្រាវជ្រាវទៅលើសំណុំរឿងតាមរយៈការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ ការសួរចម្លើយជនត្រូវចោទ ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ការស្តាប់ចម្លើយសាក្សី ការឆែកឆេរវត្ថុតាង ការចាប់យកវត្ថុតាង ការធ្វើកោសលវិច័យ ការស្តាប់ទូរស័ព្ទ និងការចេញដីកាចាត់ឱ្យស៊ើបសួរជំនួស។ លើសពីនេះទៅទៀត ព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណី និងជនត្រូវចោទ អាចស្នើសុំឱ្យចៅក្រមស៊ើបសួរធ្វើការស្រាវជ្រាវទៅលើចំណុចណាមួយដែលអាចជាភស្តុតាង ឬក៏អាចបង្ហាញភាពពិតនៃសំណុំរឿង។ ទន្ទឹមនឹងនេះ ចៅក្រមស៊ើបសួរអាចមានវិធានការនិរន្តរាយ ពោលគឺជាវិធានដែលធានាឱ្យបាននូវការជៀសវាងការអន្តរាយ ឬគ្រោះថ្នាក់ណាមួយមិនឱ្យកើតមានឡើងក្នុងដំណើរការនៃការស៊ើបសួរ តាមរយៈការចេញនូវដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំខ្លួន ដីកាបង្គាប់ឱ្យចាប់ខ្លួន ដីកាបង្គាប់ឱ្យឃុំខ្លួន និងដីកាឃុំខ្លួនបណ្តោះអាសន្ន។

នៅពេលដែលសំណុំរឿងត្រូវបានចៅក្រមស៊ើបសួរធ្វើការស្រាវជ្រាវសព្វគ្រប់ហើយ ចៅក្រមស៊ើបសួរអាចធ្វើការបិទកិច្ចស៊ើបសួររបស់ខ្លួនបាន ដោយធ្វើការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាពិនិត្យ និងរង់ចាំដីកាសន្និដ្ឋានស្ថាពរពីព្រះរាជអាជ្ញា ទើបចៅក្រមស៊ើបសួរអាចចេញដីកាដំណោះស្រាយដោយធ្វើការបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ហើយករណីប្រសិនបើមានការលើកលែងចោទប្រកាន់ទៅលើជនត្រូវចោទ ឬអញ្ញាតជនណាមួយ ត្រូវមានបង្ហាញនៅក្នុងដីកាដំណោះស្រាយ។

សរុបសេចក្តីមក ចៅក្រមស៊ើបសួរមានតួនាទីយ៉ាងសំខាន់នៅក្នុងដំណាក់កាលនៃការស៊ើបសួរចំពោះរឿងក្តីព្រហ្មទណ្ឌ ដោយបំពេញតួនាទីរបស់ខ្លួនក្នុងការស្វែងរកនូវភស្តុតាងនានាដែលពាក់ព័ន្ធនឹងសំណុំរឿង ហើយផ្តល់នូវការពិត និងយុត្តិធម៌ជូនដល់ភាគីដែលពាក់ព័ន្ធ។

# អនុសាសន៍

ក្រោយពីបានធ្វើការស្រាវជ្រាវទៅលើប្រធានបទ **“តួនាទី និងភារកិច្ចរបស់ចៅក្រមស៊ើបសួរ”** រួចមក យើងខ្ញុំសង្កេតឃើញថា មានចំណុចមួយចំនួនគប្បីគួរកែលម្អដើម្បីឱ្យការអនុវត្តក្នុងការស៊ើបសួរមានលក្ខណៈល្អប្រសើរ។ យើងខ្ញុំសូមលើកយកនូវអនុសាសន៍មួយចំនួនដូចជា៖

- ត្រូវបន្តការផ្សព្វផ្សាយឱ្យបានទូលំទូលាយស្ដីអំពីក្រមនីតិវិធីព្រហ្មទណ្ឌថ្មី ដើម្បីឱ្យប្រជាពលរដ្ឋបានយល់ដឹងកាន់តែប្រសើរ
- ត្រូវលើកទឹកចិត្តដល់ប្រជាពលរដ្ឋឱ្យចូលរួមក្នុងការសហការណ៍ ក៏ដូចជាការផ្ដល់នូវការពិតចំពោះអ្វីដែលពួកគាត់បានឃើញ ដឹង និងពាក់ព័ន្ធនឹងការពិតនៃសំណុំរឿង
- ត្រូវបន្តរក្សាឱ្យបាននូវភាពកក់ក្ដៅ និងសុវត្ថិភាពជូនដល់សាក្សីដែលបានចូលរួមក្នុងការបំភ្លឺការពិតនៅក្នុងសំណុំរឿង
- ត្រូវអនុវត្តឱ្យបានហ្មត់ចត់គ្រប់កិច្ចស៊ើបសួរ និងគោរពបទប្បញ្ញត្តិច្បាប់ឱ្យបានខ្ជាប់ខ្ជួនក្នុងនាមជាអ្នកស្វែងរកភាពយុត្តិធម៌ជូនប្រជាពលរដ្ឋ
- ត្រូវផ្ដល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋស្របតាមអភិក្រមបួនរួមមាន លឿនរហ័ស ត្រឹមត្រូវ យុត្តិធម៌ និងមិនពុករលួយ
- ត្រូវបង្កើតឱ្យមានមន្ទីរពិសោធន៍មួយនៅតាមសាលាដំបូងរាជធានី-ខេត្ត ដោយមានអ្នកជំនាញនៅប្រចាំការធ្វើការ និងបំពាក់នូវឧបករណ៍បច្ចេកទេសគ្រប់គ្រាន់ ដើម្បីសម្រួលដល់ការពិនិត្យ ធ្វើកោសលវិច័យទៅលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង ដោយកត្តានេះអាចជួយពន្លឿនក្នុងការស្រាវជ្រាវមួយកម្រិតផងដែរ។

# ឯកសារយោង


## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤។
- ច្បាប់ស្តីពី លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា, នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤។
- ច្បាប់ស្តីពី វិសោធនកម្មមាត្រា ២៤៧ មាត្រា ៣៦៨ មាត្រា ៣៧២ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៦១៣/០០៩, ០៩ មិថុនា ២០១៣។
- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧។

## ២. សៀវភៅ និងស្នាដៃនិពន្ធ

- ចក សម្បត្តិ, ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ, សមាគមសាលាត្រាជូ, ខែវិច្ឆិកា ឆ្នាំ២០១៧។
- អាន សូរីដា, ២០១១, ដំណើរការរឿងក្តីព្រហ្មទណ្ឌនៅកម្ពុជាបច្ចុប្បន្ន, ភ្នំពេញ៖ ឈើរទីម៉ិច គ្រុប។
- សុខ រឿន, ២០១០-២០១១, សៀវភៅមេរៀននីតិវិធីព្រហ្មទណ្ឌ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។
- សៀវភៅក្បួននីតិវិធីតុលាការព្រហ្មទណ្ឌ, ភ្នំពេញ, ២០០៦។

## ៣. គេហទំព័រ

- https://llundi.wordpress.com/page/3/?ref=spelling (ចូលទស្សនាថ្ងៃទី២៨ កក្កដា ២០២១)។
- http://salatraju.com/post/332 (ចូលទស្សនាថ្ងៃទី១៥ មិថុនា ២០២១)។

# បញ្ជីរាយនាមឧបសម្ព័ន្ធ

| | |
|---|---|
| ឧបសម្ព័ន្ធទី១ | ទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ |
| ឧបសម្ព័ន្ធទី២ | ទម្រង់នៃដីកាកោះ |
| ឧបសម្ព័ន្ធទី៣ | ទម្រង់នៃដីកាបង្គាប់ឱ្យឆែកឆេរលំនៅដ្ឋាន ឬ រុករកវត្ថុតាង |
| ឧបសម្ព័ន្ធទី៤ | ទម្រង់នៃដីកាបង្គាប់ឱ្យចុះពិនិត្យទីកន្លែងកើតហេតុ |
| ឧបសម្ព័ន្ធទី៥ | ទម្រង់នៃដីកាចាត់តាំងអ្នកជំនាញ |
| ឧបសម្ព័ន្ធទី៦ | ទម្រង់នៃដីកាចាត់ឱ្យស៊ើបសួរជំនួស |
| ឧបសម្ព័ន្ធទី៧ | ទម្រង់នៃដីកាផ្ទេរសមត្ថកិច្ច |
| ឧបសម្ព័ន្ធទី៨ | ទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបទល្មើសថ្មីបន្ថែម |
| ឧបសម្ព័ន្ធទី៩ | ទម្រង់នៃដីកាបង្គាប់ឱ្យចូលខ្លួន |
| ឧបសម្ព័ន្ធទី១០ | ទម្រង់នៃដីកាបង្គាប់ឱ្យនាំខ្លួនជនជាប់សង្ស័យ ឬជនល្មើស មកសួរចម្លើយ |
| ឧបសម្ព័ន្ធទី១១ | ទម្រង់នៃដីកាបង្គាប់ឱ្យចាប់ខ្លួន |
| ឧបសម្ព័ន្ធទី១២ | ទម្រង់នៃដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន |
| ឧបសម្ព័ន្ធទី១៣ | ទម្រង់នៃដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន |
| ឧបសម្ព័ន្ធទី១៤ | ទម្រង់នៃដីកាបង្គាប់ឱ្យឃុំខ្លួន |
| ឧបសម្ព័ន្ធទី១៥ | ទម្រង់នៃដីកាសម្រេចអនុញ្ញាតឱ្យនៅក្រៅឃុំបណ្តោះអាសន្ន |
| ឧបសម្ព័ន្ធទី១៦ | ទម្រង់នៃដីកាសម្រេចមិនអនុញ្ញាតឱ្យជនល្មើសនៅក្រៅឃុំជាបណ្តោះអាសន្ន |
| ឧបសម្ព័ន្ធទី១៧ | ទម្រង់នៃដីកាបង្គាប់ឱ្យដោះលែង |
| ឧបសម្ព័ន្ធទី១៨ | ទម្រង់នៃលិខិតជូនដំណឹង |
| ឧបសម្ព័ន្ធទី១៩ | ទម្រង់នៃដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យ |
| ឧបសម្ព័ន្ធទី២០ | ទម្រង់នៃដីកាបង្គាប់ឱ្យស៊ើបសួរបន្ថែម |
| ឧបសម្ព័ន្ធទី២១ | ទម្រង់នៃដីកាសន្និដ្ឋានស្ថាពរ |
| ឧបសម្ព័ន្ធទី២២ | ទម្រង់នៃដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះ |
| ឧបសម្ព័ន្ធទី២៣ | ទម្រង់នៃដីកាសម្រេចលើកលែងចោទប្រកាន់ |
| ឧបសម្ព័ន្ធទី២៤ | ទម្រង់នៃដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្នបន្ត |
| ឧបសម្ព័ន្ធទី២៥ | ទម្រង់នៃដីកាសម្រេចកែប្រែបទល្មើស |
| ឧបសម្ព័ន្ធទី២៦ | ទម្រង់នៃដីកាសម្រេចសុំចោទប្រកាន់បទល្មើសថ្មីបន្ថែម |

**ព្រះរាជាណាចក្រកម្ពុជា**

**អយ្យការអម** ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្ត-ក្រុង **********

.........................

*********** **ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ**

លេខ..................... ************

យើង.......................................... តំណាងអយ្យការអមតុលាការខេត្ត-ក្រុង .................................... ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ..................... ចុះថ្ងៃទី............ ខែ ............ ឆ្នាំ ............. និងសំណុំលិខិតភ្ជាប់មកជាមួយ ព្រមទាំងភស្តុតាងនានា ។

សម្រេចផ្ដើមចោទប្រកាន់ឈ្មោះ ......................................... ភេទ............ អាយុ ..........ឆ្នាំ ជាតិ............ របររកស៊ី....................................... ទីលំនៅបច្ចុប្បន្ននៅភូមិ...........................ឃុំ-សង្កាត់.................................. ស្រុក-ខណ្ឌ.............................................ខេត្ត-ក្រុង......................................ទោសពីមុន ........................... និងគូកន ។ ឪពុកឈ្មោះ............................................. "រ-ស" ម្ដាយឈ្មោះ ......................................... "រ-ស" ប្ដីឬប្រពន្ធឈ្មោះ..................................................."រ-ស"មានកូន ឬនៅលីវ .................................. ត្រូវជាប់ចោទពីបទ.......................................................................... ប្រព្រឹត្តនៅភូមិ................................................. ឃុំ-សង្កាត់............................ ស្រុក-ខណ្ឌ................................ ខេត្ត-ក្រុង...........................................កាលពីថ្ងៃទី .......... ខែ ................. ឆ្នាំ .................... តាមមាត្រា................................................................. នៃច្បាប់ ........................................................................................................................................................ ។

.........................................................................................................................................................

.......................................................................................................................................................

........................................................................................................................................................ ។

.........................................................................................................................................................

.......................................................................................................................................................

........................................................................................................................................................ ។

.........................................................................................................................................................

.......................................................................................................................................................

បញ្ជូនសំណុំរឿង វត្ថុតាង និងជនល្មើស "មានខ្លួន, គ្មានខ្លួន" ទៅចៅក្រមស៊ើបអង្កេត នៃតុលាការខេត្ត-ក្រុង ..... .............................................................. ដើម្បីចាត់ការតាមច្បាប់ និងស្នើសុំ ............................................... ។

ធ្វើនៅ............................ ថ្ងៃទី........... ខែ................. ឆ្នាំ.............

**ព្រះរាជអាជ្ញា**

www.llundi.wordpress.com

ឧបសម្ព័ន្ធទី២

**ព្រះរាជាណាចក្រកម្ពុជា**

**តុលាការខេត្ត-ក្រុង** ជាតិ សាសនា ព្រះមហាក្សត្រ

................................ **********

*********

**ដីកាកោះ**

លេខៈ ......................

******

យើង..............................................ចៅក្រមស៊ើបអង្កេតនៃតុលាការខេត្ត-ក្រុង ...................................

អញ្ជើញឈ្មោះ.................................................... ជា.......................................................ទីលំនៅបច្ចុប្បន្ននៅ

ភូមិ ................... ឃុំ-សង្កាត់ ............................... ស្រុក-ខណ្ឌ .............................. ខេត្ត-ក្រុង .....................

ឱ្យចូលទៅកាន់តុលាការខេត្ត-ក្រុង................................................ នៅវេលាម៉ោង ............................................

ថ្ងៃទី............. ខែ..................ឆ្នាំ.....................ដើម្បី..........................................................................................

ពីដំណើររឿងដែលពាក់ព័ន្ធនិងសំណុំរឿងព្រហ្មទណ្ឌលេខៈ ................ ចុះថ្ងៃទី ............... ខែ................ ឆ្នាំ ............

សាម៉ីខ្លួនត្រូវអញ្ជើញទៅឱ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនឹងរឿងខាងលើមក ជាមួយផង ប្រសិនបើមាន ។

ធ្វើនៅ.......................... ថ្ងៃទី..............ខែ................ ឆ្នាំ.............

**ចៅក្រមស៊ើបអង្កេត**

www.llundi.wordpress.com

យើង.............................................................................................................................................

បានប្រគល់ដីកាកោះនេះឱ្យឈ្មោះ ..........................................................................................................

ទីលំនៅបច្ចុប្បន្ននៅភូមិ......................... ឃុំ-សង្កាត់.................................ស្រុក-ខណ្ឌ.............................. ខេត្ត-ក្រុង ............................. នៅថ្ងៃទី................ ខែ.............. ឆ្នាំ...................... ហើយយើងបានប្រាប់ថា សាមីខ្លួនត្រូវប្រគល់ចុងដីកាកោះនេះ ដល់ក្រឡាបញ្ជីនៅពេលដែលខ្លួនចូលទៅចំពោះមុខតុលាការ ខេត្ត-ក្រុង................ ................................... ។

***អ្នកទទួល*** ***អ្នកប្រគល់***

ហត្ថលេខា ឬផ្តិតមេដៃ ហត្ថលេខា

---

***កំណត់សំគាល់:*** អ្នកប្រគល់ដីកានេះ ក្រោយពីអ្នកទទួលដីកាបានចុះហត្ថលេខា ឬផ្តិតមេដៃលើដីកាទាំងពីរសន្លឹករួច ហើយត្រូវប្រគល់សន្លឹក "ចុងដីកា" ទៅឱ្យអ្នកទទួល និងបង្វិលសន្លឹក "ដើមដីកា" ទៅតុលាការ ខេត្ត-ក្រុងវិញឱ្យបានមុនថ្ងៃកំណត់ក្នុងដីកា ។

www.llundi.wordpress.com

ឧបសម្ព័ន្ធទី៣

**ព្រះរាជាណាចក្រកម្ពុជា**

**តុលាការខេត្ត-ក្រុង** ជាតិ សាសនា ព្រះមហាក្សត្រ

................................ ************

***********

# ដីកាបង្គាប់ឱ្យឆែកឆេរលំនៅដ្ឋាន ឬ រុករកវត្ថុតាង[១]

លេខ..........................

***********

យើង ......................................................... ចៅក្រមស៊ើបអង្កេតនៃតុលាការខេត្ត-ក្រុង.......................................

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ............. ចុះថ្ងៃទី........... ខែ......................... ឆ្នាំ......................... ។

បានឃើញពាក្យបណ្ដឹងលេខៈ .................ចុះថ្ងៃទី............ ខែ.................. ឆ្នាំ....................របស់ .............................

...................................................................ឬចម្លើយរបស់ឈ្មោះ......................................... ជា............................... ។

យល់ឃើញថាៈ ..........................................................................................................................................

..........................................................................................................................................................

**ហេតុដូច្នេះ សម្រេច**

១. បង្គាប់មកលោក ..................................................... ជា .......................................................................

ដើម្បីចាត់ចែងចុះឆែកឆេរលំនៅដ្ឋាន ឬរុករកវត្ថុតាងនៅ ចំណុច[២] ......................................របស់ឈ្មោះ ................................

ដែលស្ថិតនៅភូមិ ........................................ឃុំ-សង្កាត់ ...................................... ស្រុក-ខណ្ឌ .........................................

ខេត្ត-ក្រុង ........................................................ ។

២. ក្រោយពីបានចុះឆែកឆេរ ឬរុករកវត្ថុតាង មន្ត្រីនគរបាលយុត្តិធម៌ ត្រូវបញ្ជូនក្នុងរយៈពេលដ៏ខ្លីបំផុតនូវកំណត់ហេតុរបស់ខ្លួនព្រមទាំងវត្ថុតាងប្រសិនបើមាន មកតុលាការខេត្ត-ក្រុង ................................................ ដើម្បីចាត់ការតាមច្បាប់ ។

ធ្វើនៅ.................... ថ្ងៃទី............ ខែ .................. ឆ្នាំ..................

**ចៅក្រមស៊ើបអង្កេត**

***កំណត់សំគាល់:*** (១).ចៅក្រមស៊ើបអង្កេតអាចចេញដីកានេះបាន លុះត្រាតែសំណុំរឿង ស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួន។

(២).បញ្ជាក់ឱ្យបានច្បាស់អំពី ឈ្មោះ និងអាសយដ្ឋាន ដែលត្រូវឆែកឆេរ ឬរុករកវត្ថុតាង ។

www.llundi.wordpress.com

**ព្រះរាជាណាចក្រកម្ពុជា**

**តុលាការខេត្ត-ក្រុង** ជាតិ សាសនា ព្រះមហាក្សត្រ

................................... ***********

*********** **ដីកាបង្គាប់ឱ្យចុះពិនិត្យទីកន្លែងកើតហេតុ**

លេខ..................... **********

យើង ......................................... ចៅក្រមស៊ើបអង្កេតនៃតុលាការខេត្ត-ក្រុង ......................................

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ................................. ចុះថ្ងៃទី .................. ខែ ............. ឆ្នាំ ..........

បានឃើញ (១) ..........................................................................................................................

...........................................................................................................................................

...........................................................................................................................................

យល់ឃើញថា (២) ...................................................................................................................

...........................................................................................................................................

...........................................................................................................................................

**ហេតុដូច្នេះ**

១. បង្គាប់មកលោក ........................................... ជាមន្ត្រីនគរបាលយុត្តិធម៌ ដឹកនាំកម្លាំងចុះពិនិត្យទីកន្លែងកើតហេតុនៅចំណុច ............................................................................ ដែលស្ថិតនៅភូមិ ................................ ឃុំ-សង្កាត់ ............................ ស្រុក-ខណ្ឌ ..................................... ខេត្ត-ក្រុង ............................................. នៅថ្ងៃទី ............... ខែ ....................... ឆ្នាំ ..................... វេលាម៉ោង ...................................................។

២. ក្រោយពីបានចុះពិនិត្យទីកន្លែងកើតហេតុ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវបញ្ជូន ក្នុងរយៈពេលដ៏ខ្លីបំផុតនូវកំណត់ហេតុរបស់ខ្លួន ព្រមទាំងវត្ថុតាងប្រសិនបើមាន មកតុលាការខេត្ត-ក្រុង .................................................................... ដើម្បីចាត់ការតាមច្បាប់។

ធ្វើនៅ........................... ថ្ងៃទី........... ខែ.................... ឆ្នាំ.........

**ចៅក្រមស៊ើបអង្កេត**

---

កំណត់សំគាល់: ១. សរសេរចុះ ពត៌មាន ពាក្យបណ្តឹង ឬរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌

២. សរសេរចុះអំពីវិធានការស៊ើបអង្កេត ដែលជាវិធានចាំបាច់ក្នុងការស្វែងរកឱ្យឃើញនូវការពិត ដើម្បីបង្ក្រាបបទល្មើស។

www.llundi.wordpress.com

**ព្រះរាជាណាចក្រកម្ពុជា**

**តុលាការខេត្ត-ក្រុង** ជាតិ សាសនា ព្រះមហាក្សត្រ

.......................... ********

******** **ដីកាចាត់តាំងអ្នកជំនាញ** [១]

លេខ .................... ********

យើង .................................... ចៅក្រមស៊ើបអង្កេតនៃតុលាការខេត្ត-ក្រុង ....................................... ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ: ................ ចុះថ្ងៃទី ............. ខែ .................. ឆ្នាំ ....................... របស់អយ្យការអមតុលាការខេត្ត-ក្រុង ........................................ ។

